https://www.facebook.com/Voangeksa

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រម
# សំណួរ-ចម្លើយ
# ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

ភ័ណ្ឌឯកសារ

https://www.facebook.com/Voangeksa

# ក្រុមខ សំណួរ – ចម្លើយ
## ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងឧរម្ភប់ប្រកាសទ្រព្យសម្បត្តិ និងបំណុល

1. សំ. តើសាច់លុយតម្រូវឱ្យប្រកាសដែរឬទេ?
   ចំ. ប្រកាសក៏បាន មិនប្រកាសក៏បាន។ ការប្រកាសសាច់លុយជាមូលដ្ឋានសម្រាប់ការឆ្លើយបំភ្លឺពីការចំណាយក្នុងការទិញ និងបណ្តាក់ទុន។ ការមិនប្រកាស មិនអាចប្រើប្រាស់សម្រាប់ជាសំអាងផ្សេងៗបានទេ។ ការប្រកាសមានការចំណេញជាងការមិនប្រកាស។ ការមិនប្រកាសលុយនៅធនាគារស្មើនឹងការប្រកាស ពីព្រោះធនាគារជាកន្លែងរក្សាទុកលុយស្របច្បាប់ ហើយការដាក់លុយនៅធនាគារធ្វើឱ្យសាច់លុយមិនហូរចេញទៅក្រៅប្រទេស។
2. សំ. តើឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវដុតបំផ្លាញចោលបន្ទាប់ពីរយៈពេល ១០ឆ្នាំមែនឬទេ ក្រោយពីការប្រគល់ជូនអង្គភាពប្រឆាំងអំពើពុករលួយ?
   ចំ. តាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវរក្សាទុកយូរបំផុតក្នុងរយៈពេល១០ឆ្នាំ។ នៅប្រទេសបារាំងឯកសារប្រកាសពន្ធត្រូវរក្សាទុកក្នុងរយៈពេល៥ឆ្នាំ។ អង្គភាពប្រឆាំងអំពើពុករលួយនឹងសម្រេចធ្វើយ៉ាងណាចំពោះឯកសារនេះបន្ទាប់ពីរយៈពេល ១០ឆ្នាំ។
3. សំ. នៅពេលយើងប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២ តើយើងអាចដកយកឯកសារលើកដំបូងពីអង្គភាពប្រឆាំងអំពើពុករលួយបានដែរឬទេ?
   ចំ. មិនបានទេ។ ប្រកាសលើកដំបូង ទី១ ទី២ ទី៣ និងបន្តបន្ទាប់ត្រូវរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ ហើយមានន័យថាការប្រគល់ជូនឯកសារលើកទី២ មិនអាចដកយកឯកសារលើកទី១ទៅវិញទេ។
4. សំ. តើប្តីប្រពន្ធដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចគ្នា អាចប្រកាសតែមួយឯកសារបានដែរឬទេ?
   ចំ. ក្នុងករណីនេះ ប្តី និងប្រពន្ធត្រូវប្រកាសដាច់ដោយឡែកពីគ្នា។ ប្តីមួយច្បាប់ និងប្រពន្ធមួយច្បាប់។ ជាការងាយស្រួល ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល អាចថតចម្លងមួយច្បាប់ទៀតសម្រាប់ប្តី ឬប្រពន្ធ តែត្រូវផ្តិតម្រាមដៃសាមីជនសម្រាប់ឯកសាររៀងៗខ្លួន។
5. សំ. តើប្រធាននាយកដ្ឋាននៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតែងតាំងដោយប្រធាន គ.ជ.ប មិនតែងតាំងដោយអនុក្រឹត្យ តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?
   ចំ. ប្រធាននាយកដ្ឋាននេះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះបុគ្គលនេះទទួលបានបុព្វសិទ្ធិ និងបៀវត្សដូចប្រធាននាយកដ្ឋាននៅក្រសួងស្ថាប័នដទៃដែរ។
6. សំ. តើតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលចាប់ពីថ្នាក់ណាឡើងទៅ?
   ចំ. មន្ត្រីនគរបាលជាតិ និងយោធា កងរាជអាវុធហត្ថ តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល ចាប់ពីឋានន្តរស័ក្តិ វរសេនីយ៍ឯក (ស័ក្តិ ៥) ទោះបីបុគ្គលនោះជាប្រធានការិយាល័យ



វាំងអក្សរ

ឬអនុប្រធាននាយកដ្ឋានដែលមិនតែងតាំងដោយអនុក្រឹត្យក៏ដោយ។

7. សំ. តើការទទួលប្រាក់ខែមិនទៀងទាត់ និងការតែងតាំងមិនដោយអនុក្រឹត្យ ចំពោះប្រធាននាយកដ្ឋាននៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

   ចំ. ទោះបីក្នុងករណីនេះក៏ដោយបុគ្គលនេះត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល។

8. សំ. តើបុគ្គលដែលមានចិញ្ចៀនមួយវង់មានតម្លៃតិចជាង ៨លានរៀល តម្រូវឱ្យប្រកាសដែរឬទេ?

   ចំ. បើចិញ្ចៀនខាងលើមានតម្លៃតិចជាង ៨លានរៀល បុគ្គលនោះមិនចាំបាច់ប្រកាសទេ។ ការប្រកាសលុះត្រាតែចិញ្ចៀននោះមានតម្លៃស្មើ ឬច្រើនជាង៨លាន។

9. សំ. តើអលង្ការដែលតម្រូវឱ្យប្រកាស ត្រូវកំណត់យកប្រភេទណាខ្លះ?

   ចំ. ក្នុងការប្រកាសលើកដំបូងនេះ អលង្ការសំដៅតែអ្វីដែលនៅជុំវិញក, កដៃ, ម្រាមដៃ, និងត្រចៀកសម្រាប់ស្ត្រី (បើអ្នកប្រកាសជាបុរសដែលមានក្រវិលត្រូវប្រកាសដែរ) តែប៉ុណ្ណោះ និងមានតម្លៃចាប់ពី ៨លានរៀលឡើងទៅ។ ចំពោះអ្វីដែលនៅជុំវិញចង្កេះ កជើង ម្រាមជើង ពីនតា ខ្សែក្រវាត់ និងកន្លែងផ្សេងៗទៀតមិនទាន់តម្រូវឱ្យប្រកាសនាពេលនេះទេ ទោះបីរបស់របរទាំងនោះមានតម្លៃលើស ៨លានរៀល និងអាចចាត់ទុកជាប្រភេទអលង្ការក៏ដោយ។

10. សំ. តើអាចារ្យដែលតែងតាំងដោយអនុក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

    ចំ. បើការតែងតាំងនេះ មិនមែនជាងារ តែជាមុខងារសាធារណៈ បុគ្គលនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលជាធម្មតា។

11. សំ. តើតុលាការមិនអាចបញ្ជាឱ្យអង្គភាពប្រឆាំងអំពើពុករលួយផ្តល់ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល សម្រាប់ជាសំអាងក្នុងករណីលែងលះបានដែរឬទេ?

    ចំ. យោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពមានបុព្វសិទ្ធិបើកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលតែក្នុងករណីស៊ើបអង្កេតអំពើពុករលួយតែប៉ុណ្ណោះ។ ដូច្នេះ អង្គភាពប្រឆាំងអំពើពុករលួយមិនអាចប្រគល់ឯកសារនេះ ជូនតុលាការលើបុព្វហេតុសម្រេចសេចក្តីចំពោះករណីលែងលះបានទេ។

12. សំ. តើលិខិតបញ្ជាក់ម្ចាស់អចលនវត្ថុ តម្រូវឱ្យថតចម្លងជូនភ្ជាប់មកជាមួយនឹងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

    ចំ. លិខិតទាំងនេះ មិនតម្រូវឱ្យជូនភ្ជាប់មកជាមួយឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ ព្រោះស្រោមសំបុត្រប្រកាសទ្រព្យសម្បត្តិ និងបំណុលមិនអាចផ្ទុកឯកសារទាំងនេះបានគ្រប់ចំនួនទេ ហើយបើមានការបើកស្រោមសំបុត្រសម្រាប់ការស៊ើបអង្កេត ទើបតម្រូវឱ្យយកមកផ្ទៀងផ្ទាត់។

13. សំ. តើចំណូលពីអាជីវកម្ម និងពាណិជ្ជកម្ម អាចប្តូរមកដាក់ក្នុងចំណុចសាច់ប្រាក់បានដែរឬទេ?

    ចំ. ចំណូលប្រភេទនេះអាចដាក់ក្នុងចំណុចសាច់ប្រាក់បាន តែអ្នកប្រកាសទ្រព្យសម្បត្តិ



វ៉ាន់ឯកសារ

និងបំណុល ត្រូវប្រកបមុខរបរអាជីវកម្ម និងពាណិជ្ជកម្មណាដែលមិនត្រូវបានហាមឃាត់ដោយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

14. សំ. តើកម្រៃដែលបានមកពីការធ្វើជាទីប្រឹក្សា នៅកន្លែងផ្សេង តម្រូវឱ្យប្រកាសដែរឬទេ?

ចំ. កម្រៃនេះត្រូវប្រកាស កុំឱ្យតែមុខងារជាទីប្រឹក្សានេះ មានទំនាស់ផលប្រយោជន៍ជាមួយមុខងារបច្ចុប្បន្នជាមន្ត្រី។ ឧទាហរណ៍ មន្ត្រីនគរបាលមិនអាចបើកក្លឹងស៊ីទទួលបញ្ចាំបានទេ។ ចំណូលដែលបានមកពីមុខងារខាងលើ ត្រូវបង់ពន្ធតាមច្បាប់កំណត់ ដើម្បីឱ្យចំណូលនេះក្លាយទៅជាចំណូលស្របច្បាប់។

15. សំ. តើបុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលមានឋានន្តរសក្តិ វរសេនីយ៍ឯក និងដែលមានងារជានកញ្ញា តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ ?

ចំ. បុគ្គលនេះត្រូវប្រកាស ទ្រព្យសម្បត្តិ និងបំណុល ព្រោះមានឋានន្តរសក្តិដែលជាប់កាតព្វកិច្ចប្រកាស។ បើបុគ្គលនេះជានកញ្ញាសុទ្ធសាធ មិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ។ នកញ្ញាគ្រាន់តែជាងារ មិនមែនជាមន្ត្រីសាធារណៈ។

16. សំ. តើទ្រព្យដែលជាអំណោយរបស់ឪពុកម្តាយ តម្រូវឱ្យដាក់តម្លៃដូចម្តេច?

ចំ. តម្លៃនៃទ្រព្យនេះ អាចដាក់ ០ដុល្លារបាន ព្រោះឪពុកម្តាយជាអ្នកផ្តល់ឱ្យ ដោយមិនទាមទារនូវតម្លៃណាមួយពីអ្នកដែលគាត់ប្រគល់ឱ្យ។

17. សំ. តើដីធ្លីដែលមានឈ្មោះតែប្តី តែលុយជាលុយរួមប្តីប្រពន្ធ តម្រូវឱ្យប្រកាសដូចម្តេច?

ចំ. ទោះបីជាលុយរួមប្តីប្រពន្ធ (ទ្រព្យសម្បត្តិរួម)ក៏ដោយ បុគ្គលជាប្តីតម្រូវឱ្យប្រកាសតែឈ្មោះប្តីទេ មិនត្រូវបញ្ចូលឈ្មោះប្រពន្ធក្នុងនាមជាសហកម្មសិទ្ធិករឡើយ។

18. សំ. តើសាច់លុយដែលបានប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវជាប់កាតព្វកិច្ចបង់ពន្ធដែរទេ?

ចំ. ការកំណត់យកពន្ធ ឬមិនយកពន្ធ ជាភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានពន្ធដារ) អង្គភាពប្រឆាំងអំពើពុករលួយមិនមានភារកិច្ចលើការកំណត់នៃការយកពន្ធនេះទេ។ លើការជាក់ស្តែង កាតព្វកិច្ចបង់ពន្ធ អនុវត្តតែលើប្រាក់ចំណេញតែប៉ុណ្ណោះ។ រដ្ឋសភាអាចចេញច្បាប់ស្តីពីការយកពន្ធលើសាច់ប្រាក់ខាងលើនេះផងដែរ ។

19. សំ. តើសមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈដែលតែងតាំងដោយអនុក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. សមាជិកនៃក្រុមប្រឹក្សាភិបាលនេះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ទោះបីតួនាទីដើមរបស់គាត់តែងតាំងដោយប្រកាសក៏ដោយ។

20. សំ. តើការស៊ើបអំពើពុករលួយអនុវត្តលើបុគ្គលដែលបានស្លាប់ហើយដែរឬទេ?

ចំ. ការស៊ើបអង្កេតអំពើពុករលួយ មិនអនុវត្តលើបុគ្គលដែលបានស្លាប់នោះទេ។

21. សំ. តើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ គ្របដណ្តប់លើអ្នកកាន់សាសនាដែរឬទេ?

ចំ. ច្បាប់នេះមិនគ្របដណ្តប់លើសកម្មភាពរបស់អ្នកកាន់សាសនាទេ តែបើសាសនិកនោះបានប្រព្រឹត្តបទល្មើសពុករលួយណាមួយដែលមានចែងក្នុងច្បាប់នេះ បុគ្គលនោះត្រូវទទួលរងនូវការ



វ៉ាងអេកសា

ទោសទណ្ឌពីច្បាប់នេះ ដូចប្រជាពលរដ្ឋធម្មតាដែរ។

22. សំ. តើព្រះសង្ឃដែលតែងតាំងជាអគ្គាធិការ ឬសកលវិទ្យាធិការ ប្រធាននាយកដ្ឋាន ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. ព្រះសង្ឃដែលបានតែងតាំងដូចករណីខាងលើនេះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះព្រះអង្គទទួលបៀវត្ស និងបុព្វសិទ្ធិពីតួនាទីនេះ។ បើការតែងតាំងព្រះសង្ឃជាងារ មិនមែនជាមុខងារសាធារណៈ មិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ។

23. សំ. តើអង្គភាពប្រឆាំងអំពើពុករលួយ អាចស៊ើបអង្កេតព្រះសង្ឃដែលប្រព្រឹត្តពុករលួយបានដូចប្រជាពលរដ្ឋធម្មតាដែរឬទេ?

ចំ. បុគ្គលណាក៏ដោយដែលប្រព្រឹត្តបទល្មើសពុករលួយ អង្គភាពមានបុព្វសិទ្ធិស៊ើបអង្កេតបានទាំងអស់ ទោះបីបុគ្គលនោះ ជាព្រះសង្ឃក៏ដោយ។

24. សំ. តើការខ្ចីលុយពីធនាគារ តម្រូវឱ្យប្រកាសដែរឬទេ?

ចំ. ការខ្ចីលុយនេះមិនតម្រូវឱ្យប្រកាសទេ ពីព្រោះជាលុយដែលយើងជំពាក់គេ យើងប្រកាសតែលុយដែលគេជំពាក់តែប៉ុណ្ណោះ។

25. សំ. នៅពេលដែលជំពូកទី៦នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមិនទាន់ចូលជាធរមាន តើ ACU អាចរឹបអូសទ្រព្យសម្បត្តិដែលបានមកពីអំពើពុករលួយបានដែរឬទេ?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយអាចរឹបអូសទ្រព្យសម្បត្តិដែលបានមកអំពើពុករលួយ ព្រោះច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ បានកំណត់ពីការរឹបអូសនេះ។

26. សំ. តើការឆ្លើយថាប្រពន្ធឱ្យលុយចុះមូលដ្ឋាន ចាត់ទុកជារឿងត្រឹមត្រូវ និងស្របច្បាប់ដែរឬទេ?

ចំ. ការឆ្លើយនេះជារឿងមួយដែលត្រឹមត្រូវ និងស្របច្បាប់ ហើយអង្គភាពមិនមានសិទ្ធិស៊ើបអង្កេតលុយដែលប្រពន្ធផ្តល់ឱ្យនោះទេ។

27. សំ. តើព្រះសង្ឃដែលត្រូវបានតែងតាំងជាងារ ដោយព្រះរាជក្រឹត្យ តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. មិនតម្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ ដូចករណីការតែងតាំងងារជានកញ្ញាដែរ។

28. សំ. តើក្រុមជនបង្គោលអាចមានត្រាដោយឡែកសម្រាប់បំពេញការងាររបស់ខ្លួនដែរឬទេ?

ចំ. ក្រុមជនបង្គោលមិនមានត្រាដោយឡែកសម្រាប់ការងាររបស់ខ្លួនទេ ហើយតួនាទីរបស់ក្រុមជនបង្គោលជាការបន្ថែមភារកិច្ច។

29. សំ. តើសំលៀកបំពាក់នៃស្រោមសំបុត្រដែលបិទភ្ជាប់ជាមួយនឹងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលអាចជាឯកសណ្ឋាន ឬធម្មតា?

ចំ. សំលៀកបំពាក់នៃរូបថតនេះ អាចជាឯកសណ្ឋានក៏បាន និងធម្មតាក៏បាន។

30. សំ. តើធ្វើដូចម្តេចបានជាអង្គភាពប្រឆាំងអំពើពុករលួយ អាចដឹងពីកំណើនទ្រព្យសម្បត្តិរបស់បុគ្គលមួយនៅពេលដែលគាត់លាលែងពីតំណែង បើការប្រកាសនេះជាការសម្ងាត់?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយ មិនអាចដឹងពីកំណើនទ្រព្យសម្បត្តិរបស់បុគ្គលណាមួយទោះបីមានប្រកាសទ្រព្យសម្បត្តិ និងបំណុល ក្រោយការលាលែងពីតំណែងក៏ដោយ លើកលែងតែករណី

ស៊ើបអង្កេតដែលតម្រូវឱ្យអង្គភាពប្រឆាំងអំពើពុករលួយបើកស្រោមសំបុត្រ ទើបដឹងថាបុគ្គលនោះមានកំណើនទ្រព្យសម្បត្តិ។

31. សំ. តើសមាជិកនៃគណៈកម្មាធិការជាតិណាមួយដែលតែងតាំងដោយអនុក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. បើការតែងតាំងនោះគ្រាន់តែជាការតែងតាំងដើម្បីបន្ថែមលើតួនាទីបច្ចុប្បន្ន មិនបញ្ជាក់ថាមានឋានៈស្មើអ្វីមួយទេនោះ មិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ តែបើមានឋានៈ តួនាទី និងមុខងារច្បាស់លាស់ បុគ្គលនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល។

32. សំ. ច្បាប់តម្រូវឱ្យរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទាំងលើកទី១,២,៣,៤,៥ ក្នុងរយៈពេល ១០ឆ្នាំ តើពេលដែលឯកសារទាំងនោះដល់រយៈពេលកំណត់ខាងលើ ត្រូវដុតចោលឬយ៉ាងណា?

ចំ. ច្បាប់តម្រូវឱ្យអង្គភាពប្រឆាំងអំពើពុករលួយ រក្សាទុកឯកសារទាំងនោះក្នុងរយៈពេល ១០ឆ្នាំ តែត្រង់ថាដល់រយៈពេលកំណត់ខាងលើ ឯកសារទាំងនោះត្រូវដុតចោល ឬយ៉ាងណានោះ ច្បាប់មិនបានកំណត់ឱ្យធ្វើយ៉ាងណានោះទេ។

33. សំ. តើក្រោយពេលបញ្ចប់ពីតំណែង សាមីខ្លួនអាចសុំដកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលពីអង្គភាពប្រឆាំងអំពើពុករលួយបានដែរឬទេ?

ចំ. ករណីនេះ សាមីខ្លួនមិនមានសិទ្ធិសុំដកឯកសារនេះបានទេ ព្រោះច្បាប់មិនបានចែងថាត្រូវប្រគល់ឱ្យសាមីខ្លួនវិញឡើយ។

34. សំ. តើការដេញថ្លៃជាការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយដែរឬទេ?

ចំ. ការងារដេញថ្លៃទាំងឡាយអង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិចូលរួមដើម្បីធានាថាការដេញថ្លៃទាំងនោះមានលក្ខណៈត្រឹមត្រូវ។ អង្គភាពអាចចាត់វិធានការស្របច្បាប់ណាមួយក្នុងករណីដែលពិនិត្យឃើញថា ការដេញថ្លៃមានភាពមិនប្រក្រតី។ ក្រុមជនបង្គោលក៏ត្រូវចូលរួមក្នុងកិច្ចការនេះដែរ។

35. សំ. តើមន្ត្រីដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ហើយត្រូវបានបញ្ជូនទៅសិក្សានៅក្រៅប្រទេស តម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ? បើប្រកាសត្រូវធ្វើតាមមធ្យោបាយណា?

ចំ. មន្ត្រីខាងលើនេះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមន្ត្រីនៅក្នុងស្រុកដែរ។ ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលអាចផ្ញើតាមប្រអប់សំបុត្រប្រៃសណីយ៍ ឬស្ថានទូតមកអង្គភាពប្រឆាំងអំពើពុករលួយផ្ទាល់ ដោយកាលបរិច្ឆេទនៃការទទួលឯកសារនេះ គិតចាប់ពីថ្ងៃដែលបុគ្គលនោះបានដាក់ផ្ញើមក។ ឯកសារនេះអាចផ្ញើតាមរយៈក្រុមជនបង្គោលនៃក្រសួងស្ថាប័ននីមួយៗ ព្រោះក្រុមជនបង្គោលជាអ្នកផ្តល់ដំណឹង និងការពារប្រយោជន៍ជូនបុគ្គលទាំងនោះ។

36. សំ. តើសេនានុព័ន្ធយោធា និងមន្ត្រីការិយាល័យពាណិជ្ជកម្មប្រចាំស្ថានទូតកម្ពុជានៅក្រៅប្រទេសត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅតាមក្រសួងដើម ឬក្រសួងការបរទេស



វ៉ាំងឯកសារ

https://www.facebook.com/Voangeksa
និងសហប្រតិបត្តិការអន្តរជាតិ ?

ចំ. មន្ត្រីទាំងនេះត្រូវ ប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈក្រុមជនបង្គោលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រោះការប្រកាសនេះ ដោយសំអាងលើតួនាទីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

37. សំ. មន្ត្រីដែលមានក្របខ័ណ្ឌដើមនៅក្រសួងផ្សេង តែត្រូវបានតែងតាំងដោយអនុក្រឹត្យជាមន្ត្រីការទូតកម្ពុជាប្រចាំនៅក្រៅប្រទេស តើត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. មន្ត្រីទាំងនេះមានកាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះគាត់តែងតាំងដោយអនុក្រឹត្យ។

38. សំ. តើចេតិយត្រូវប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. ចេតិយដែលមិនមានការអនុញ្ញាតឱ្យធ្វើប្លង់កម្មសិទ្ធិ ឬដីសាធារណៈ មិនតម្រូវឱ្យប្រកាសទេ តែបើចេតិយនោះ សាងសង់នៅលើដីដែលអាចមានប្លង់កម្មសិទ្ធិ គឺត្រូវប្រកាសតែដី។

39. សំ. តើចំណូលពីការល្បែងនៅកាស៊ីណូ ជាចំណូលស្របច្បាប់ដែរឬទេ?

ចំ. យើងត្រូវដឹងពីអត្តសញ្ញាណនៃបុគ្គលនោះជាជនជាតិខ្មែរ ឬបរទេស និងទីកន្លែងដែលកាស៊ីណូនោះស្ថិតនៅ។ ច្បាប់មិនអនុញ្ញាតជនជាតិខ្មែរដែលចូលលេងកាស៊ីណូក្នុងស្រុក ដូចនេះចំណូលរបស់ប្រជាពលរដ្ឋខ្មែរដែលបានមកពីកាស៊ីណូនៅក្នុងស្រុក ជាចំណូលខុសច្បាប់ តែបើចំណូលបានមកពីកាស៊ីណូនៅក្រៅប្រទេសដែលច្បាប់បានអនុញ្ញាត ចំណូលនេះជាចំណូលស្របច្បាប់។ ឧទាហរណ៍ ចំណូលដែលជនជាតិខ្មែរបានពីការល្បែងនៅកាស៊ីណូ LAS VEGAS សហរដ្ឋអាមេរិក ។ ដូចគ្នានេះដែរ ចំណូលរបស់ជនជាតិបរទេសពីការល្បែងនៅកាស៊ីណូក្នុងស្រុកខ្មែរ ជាចំណូលស្របច្បាប់។

40. សំ. តើលុយដែលបានមកពីគ្រឿងញៀនអាចប្រកាសបានដែរឬទេ?

ចំ. គ្រប់សកម្មភាពចំពោះគ្រឿងញៀនទាំងអស់ត្រូវបានច្បាប់ហាមឃាត់ ដូចនេះលុយដែលបានមកពីគ្រឿងញៀនជាលុយមិនស្របច្បាប់ និងមិនអាចប្រកាសបានទេ។

41. សំ. បើឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់សាមីខ្លួន និងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលតម្កល់ទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ មានខ្លឹមសារខុសគ្នា តើឯកសារណាមួយដែលលក្ខណៈផ្លូវការជាង?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយ រក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងលក្ខខណ្ឌត្រឹមត្រូវ និងមានសុវត្ថិភាព។ ឯកសារនេះត្រូវធានាបាននូវការសម្ងាត់ខ្ពស់បំផុត។ បើមានករណីខុសខ្លឹមសារគ្នាដូចខាងលើ ឯកសារដែលតម្កល់ទុកនៅអង្គភាពប្រឆាំងអំពើពុករលួយជាឯកសារដែលមានលក្ខណៈផ្លូវការអាទិភាពជាង។

42. សំ. ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ បានកំណត់ឱ្យក្រុមជនបង្គោលធ្វើរបាយការណ៍ទៀងទាត់របស់ខ្លួន ផ្ញើមកអង្គភាពប្រឆាំងអំពើពុករលួយ តើត្រូវធ្វើក្នុងរយៈពេលទៀងទាត់ណាមួយ?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយកំណត់ធ្វើរបាយការណ៍នេះក្នុងរយៈពេល ៣ខែ ឬ៦ខែម្តង។



វិចិត្រឯកសារ

របាយការណ៍នេះត្រូវឆ្លងការត្រួតពិនិត្យ និងឯកភាពពីប្រធានក្រសួង ស្ថាប័នសាមី ទើបផ្ញើជូនអង្គភាពជាក្រោយ។

43. សំ. តើចំណូលពីការលក់គោ ជ្រូក មាន់ ទា ត្រូវប្រកាសដែរឬទេ?

ចំ. ចំណូលពីការលក់សត្វទាំងនេះត្រូវប្រកាសក្នុងចំណុចទី៧ស្តីពីចំណូល។ តម្លៃអាចប៉ាន់ស្មានបាន។

44. សំ. បើជាសមាជិករាជរដ្ឋាភិបាលផង និងរដ្ឋសភាផង តើត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅកន្លែងណាមួយ?

ចំ. អ្នកប្រកាសត្រូវធ្វើនៅខាងរាជរដ្ឋាភិបាល ព្រោះ សមាជិករាជរដ្ឋាភិបាលមានលក្ខខណ្ឌតឹងរ៉ឹង និងមានវិសមិតភាពការងារច្រើនជាងសមាជិករដ្ឋសភា។

45. សំ. តើបុគ្គលមួយមានលុយពិតប្រាកដត្រឹមតែ ៤០ម៉ឺនដុល្លារ អាចប្រកាសថាមាន ២លានដុល្លារបានដែរឬទេ? ហើយបើអង្គភាពប្រឆាំងអំពើពុករលួយគេឃើញថា មានការប្រកាសខុសពីការពិត តើបុគ្គលនោះមានទោសដែរឬទេ?

ចំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលមិនត្រឹមត្រូវជាបទល្មើសមួយដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងដែលអាចទទួលទោសពី១ខែ ទៅ១ឆ្នាំ និងមានវិន័យជាប្រាក់ទៀតផង។ បើប្រកាស២លាន ជាក់ស្តែងមានតែ៤០ម៉ឺន មានន័យថាបុគ្គលនោះប្រកាសមិនត្រឹមត្រូវ។ ទ្រព្យសម្បត្តិមិនត្រូវថយមិនត្រូវយកមកពិចារណាទេ តែបើកើនឡើងទើបជាបុព្វហេតុនៃការស៊ើបអង្កេត។

46. សំ. អ្វីដែលចែងក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយផង និងមានចែងក្នុងក្រមព្រហ្មទណ្ឌផង តើមួយណាមានអាទិភាពខ្ពស់ជាង ?

ចំ. ក្រមព្រហ្មទណ្ឌជាច្បាប់គោល ។ តែបើពាក់ព័ន្ធនឹងអំពើពុករលួយ ច្បាប់ស្តីពីការប្រឆាំងពុករលួយមានអាទិភាពជាងក្រមព្រហ្មទណ្ឌ ព្រោះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយជាច្បាប់ព្រហ្មទណ្ឌពិសេសដែលមានអាទិភាពជាងច្បាប់ព្រហ្មទណ្ឌធម្មតា។។

47. សំ.បើលុយជារបស់ប្រពន្ធទាំងអស់ តែ ពេលធ្វើប្លង់ដីមានឈ្មោះប្តីដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល តើត្រូវប្រកាសដែរឬទេ?

ចំ.ករណីប្តីជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ប្តីត្រូវប្រកាស ព្រោះមានឈ្មោះរបស់ប្តី។ បើប្តីមិនប្រកាស មិនត្រឹមត្រូវទេ ទោះបីលុយជារបស់ប្រពន្ធក៏ដោយ។

48. សំ.តើចំណូលពីចងការប្រាក់ ឬការលេងទុងទីន អាចប្រកាសបានឬទេ? បើបានដាក់នៅចំណុចណា?

ចំ. ចំណូលពីការចងការប្រាក់ ឬការលេងទុងទីន អាចប្រកាសបាន និងដាក់នៅចំណុចទី៧ស្តីពីចំណូល ។

49. សំ. តើទីប្រឹក្សាដែលតែងតាំងចាប់ពីអនុក្រឹត្យឡើង ហើយអស់អាណត្តិការងារមុនការប្រកាសទ្រព្យសម្បត្តិ និងបំណុល តម្រូវឱ្យប្រកាសប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែរឬទេ?

ចំ. បើការបញ្ចប់អាណត្តិនោះ មិនស្ថិតក្នុងការកំណត់របស់ច្បាប់ទេ បុគ្គលនោះមិនតម្រូវឱ្យប្រកាស

ទ្រព្យសម្បត្តិ និងបំណុល ។ ឧទាហរណ៍បុគ្គលម្នាក់ដែលនឹងត្រូវចូលនិវត្តនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះការឈប់ទទួលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១។

50. សំ. តើមន្ត្រីដែលលាលែងពីតំណែងទៅចូលរួមឃោសនាការបោះឆ្នោត ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. មន្ត្រីនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះច្បាប់តម្រូវឱ្យប្រកាសយ៉ាងយូរក្រោយ៣០ថ្ងៃ ក្រោយពេលចូលកាន់មុខតំណែង និងយ៉ាងយូរ ៣០ថ្ងៃ មុន ឬក្រោយការចាកចេញពីមុខតំណែង។

51. សំ. នៅពេលត្រូវការឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សាមីខ្លួន តើអាចសុំថតចម្លងឯកសារនេះពីអង្គភាពប្រឆាំងអំពើពុករលួយបានដែរឬទេ?

ចំ. សាមីខ្លួនអាចអនុញ្ញាតឱ្យថតចម្លងឯកសារនេះដោយខ្លួនឯងផ្ទាល់នៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយដោយមន្ត្រីអង្គភាពជាអ្នកឃ្លាំមើល និងមិនអនុញ្ញាតឱ្យថតចម្លងនៅខាងក្រៅទេ។

52. សំ. តើទាំងក្រុមជនបង្គោល និងទាំងអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើការស៊ើបអង្កេតរាល់ការដេញថ្លៃដែរឬទេ?

ចំ. ក្រុមជនបង្គោលមានភារកិច្ចបង្ការ ទប់ស្កាត់ រាល់សកម្មភាពមិនប្រក្រតីក្នុងការងារដេញថ្លៃ។ បើមានករណីដេញថ្លៃមិនត្រឹមត្រូវ ក្រុមជនបង្គោលនេះអាចផ្តល់ព័ត៌មាននេះជូនមកអង្គភាពប្រឆាំងអំពើពុករលួយដើម្បីមានវិធានការបន្ត។

53. សំ. តើប្រាក់បំណាច់ប្រឆាំងអំពើពុករលួយពិតជាផ្តល់ជូនក្នុងកម្រិតខ្ពស់មែនដែរឬទេ?

ចំ. ប្រាក់បំណាច់នេះ បើយោងតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីការគ្រប់គ្រង និងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ សម្តេចនាយករដ្ឋមន្ត្រីនឹងពិនិត្យ និងសម្រេច តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានស្នើសុំពីប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

54. សំ. តើក្រុមជនបង្គោលអាចទទួលប្រាក់រង្វាន់នៃការប្រឆាំងអំពើពុករលួយបានដែរឬទេ?

ចំ. ប្រាក់រង្វាន់នឹងផ្តល់ជូនអ្នកចូលរួមការប្រឆាំងអំពើពុករលួយ និងអ្នកសហការ អ្នកផ្តល់ព័ត៌មាន និងប្រភពទាំងឡាយ។ ក្នុងន័យនេះក្រុមជនបង្គោលក៏អាចទទួលប្រាក់នេះបានដែរ។

55. សំ. តើអ្នកដែលមិនជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវអនុវត្តច្បាប់ស្តីពីការប្រឆាំងពុករលួយដែរឬទេ?

ចំ. តាមគោលការណ៍នៃការអនុវត្តជាសកលនៃច្បាប់ ទោះបីជាបុគ្គលណាក៏ដោយ អ្នកដែលមិនជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលក៏ដោយ ត្រូវអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដូចគ្នា។

56. សំ. មុនការលាលែងពីតំណែង ៣០ថ្ងៃ តើត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. យោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អ្នកប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវប្រកាស ៣០ថ្ងៃ យ៉ាងយូរមុនការលាលែងពីតំណែង ឬ៣០ថ្ងៃយ៉ាងយូរក្រោយពីការបញ្ឈប់

ពីតំណែង។

57. សំ. តើទ្រព្យសម្បត្តិជាដីធ្លីដែលមានតែឈ្មោះអ្នកដទៃគ្មានឈ្មោះយើង តែមានចំណែកលុយរបស់យើងដែរ តម្រូវឱ្យប្រកាសដែរឬទេ?

ចំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលអនុវត្តតែលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សាមីជនតែប៉ុណ្ណោះ បើមានតែឈ្មោះអ្នកដទៃ គឺមិនមានការប្រកាសឈ្មោះយើងទេ ហើយបើពីផ្ដាំក្រោយអាចយកមកដាក់ក្នុងប្រកាសបាន បើមានឈ្មោះយើងវិញ។

58. សំ. តើប្រធាននាយកដ្ឋាន ឬអគ្គនាយករង នៃសហគ្រាសសាធារណៈ ដែលតែងតាំងដោយសេចក្ដីសម្រេចរបស់អគ្គនាយកនៃសហគ្រាសសាធារណៈនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. ប្រធាននាយកដ្ឋាន ឬអគ្គនាយកនៃសហគ្រាសសាធារណៈដែលទទួលបៀវត្ស និងមានបុព្វសិទ្ធិខាងលើនេះត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល។

59. សំ. នៅក្នុងច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ការប្រកាសទ្រព្យសម្បត្តិ និងបំណុលអាចធ្វើតាមទម្រង់អេឡិចត្រូនិក។ តើយើងអាចប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមទម្រង់អេឡិចត្រូនិកបានដែរឬទេ?

ចំ. ក្នុងដំណាក់ដំបូងនេះ ការអនុវត្តតាមទម្រង់អេឡិចត្រូនិក គឺមិនទាន់មានដំណើរការអនុវត្តនៅឡើយទេ។ យើងអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុលដោយធ្វើជាលិខិតពីរច្បាប់ដាច់ដោយឡែកពីគ្នា តែមានខ្លឹមសារដូចគ្នា ដែលមួយច្បាប់រក្សាទុកនៅសាមីខ្លួន និងមួយច្បាប់ទៀតរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ។

60. សំ. តើប្រធាន ឬសមាជិកនៃក្រុមជនបង្គោលអាចធ្វើជាប្រធាន ឬសមាជិកនៃគណៈកម្មការដេញថ្លៃបានដែរឬទេ?

ចំ. បើជាប្រធាន ឬសមាជិកនៃក្រុមជនបង្គោលមិនអាចជាប្រធាន ឬសមាជិកនៃគណៈកម្មការដេញថ្លៃបានទេ បុគ្គលនេះអាចបំពេញតួនាទីតែមួយកន្លែង បើបម្រើការងារទាំងពីរកន្លែងនាំឱ្យមានទំនាស់ផលប្រយោជន៍ ឬវិសមិតភាពការងារ។

61. សំ. កន្លងមកមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយបានស៊ើបអង្កេត និងឃាត់ខ្លួនព្រះរាជអាជ្ញាខេត្តពោធិ៍សាត់ ចុះបើមន្ត្រីអង្គភាពនេះប្រព្រឹត្តអំពើពុករលួយ តើមានបុគ្គលណាជាអ្នកស៊ើបអង្កេត និងចាប់មន្ត្រីទាំងនោះវិញ?

ចំ. សម្ដេចនាយករដ្ឋមន្ត្រីជាអ្នកត្រួតពិនិត្យ និងឃ្លាំមើលនូវសកម្មភាពរបស់ប្រធាន និងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។ មន្ត្រីនៃអង្គភាពដែលប្រព្រឹត្តអំពើពុករលួយនឹងត្រូវស៊ើបអង្កេត និងចាប់ខ្លួនដោយផ្នែកស៊ើបអង្កេតផ្ទៃក្នុងនៃអង្គភាពប្រឆាំងអំពើពុករលួយ។

62. សំ. ក្រុមហ៊ុនឯកជនមួយដែលផ្ដល់ជំនួយសម្រាប់កសាងផ្លូវមួយខ្សែនៅមូលដ្ឋានដែលជាគំនិតផ្ដួចផ្ដើមរបស់ក្រសួងមួយ តើអំពើពុករលួយដែរឬទេ?

ចំ. បើជំនួយដែលមិនបណ្ដាឱ្យមានការតបស្នងវិញ មិនមែនជាអំពើពុករលួយទេ។ ឧទាហរណ៍ខាងលើ បើជំនួយនេះធ្វើឡើងដើម្បីទទួលបាននូវការផ្ដល់ត្រឡប់វិញនូវសេវាសាធារណៈ



វិទ្យាគារ

https://www.facebook.com/Voangeksa

ណាមួយពីក្រសួងនោះ ដូចជាលិខិតអនុញ្ញាត វិញ្ញាបនបត្រ... វាជាអំពើពុករលួយ តែបើគ្មានទទួលបាននូវផលប្រយោជន៍ណាមួយពីក្រសួងខាងលើទេ វាមិនមែនជាអំពើពុករលួយឡើយ។

63. សំ. តើទ្រព្យសម្បត្តិដែលជាមរតករបស់ម្តាយ ត្រូវបញ្ចូលក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. ទ្រព្យសម្បត្តិដែលជាមរតករបស់ម្តាយត្រូវតែប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល។

64. សំ. តើដីដែលត្រូវគេឈ្លោះពេលនេមរកូមិនយកធ្វើជាបន្ទាយ ត្រូវប្រកាស ឬទេ?

ចំ. ដីដែលកំពុងមានទំនាស់ និងប្តឹងផ្តល់គ្នានៅតុលាការ ត្រូវប្រកាស។ ករណីនេះក៏ត្រូវប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរ ព្រោះបើថ្ងៃក្រោយដីទាំងនេះត្រូវបានតុលាការ ឬស្ថាប័នមានសមត្ថកិច្ចណាមួយប្រគល់ឱ្យយើង គឺយើងបានប្រកាសក្នុងឯកសាររួចហើយ ហើយមិនចាំបាច់បញ្ជាក់ពីប្រភពហិរញ្ញប្បទានទៀតផង។

65. សំ. ចំណូលពីចំការ និងមុខរបរប្រចាំថ្ងៃដែលទទួលបាននូវកម្រៃតិចតួច និងដែលគ្មានវិក្កយបត្រ តើត្រូវប្រកាសឬទេ?

ចំ. ការប្រកាសមានផលប្រយោជន៍ជាងការមិនប្រកាស។ តម្លៃយើងអាចប៉ាន់ស្មានបាន។ បើយើងមិនប្រកាសគឺមិនអាចយកមកធ្វើជាសំអាងសម្រាប់ការពង្រីកទុនទៅថ្ងៃក្រោយបានទេ។

66. សំ. ចំណូលដែលមិនបានបង់ពន្ធជូនរដ្ឋ តើត្រូវប្រកាស ឬទេ?

ចំ. ច្បាប់តម្រូវឱ្យបង់ពន្ធលើប្រភេទចំណូលដែលបានកំណត់ ដូចជា ពន្ធលើបៀវត្ស ពន្ធលើផលចំណេញ ពន្ធលើការប្រាក់នៃប្រាក់ក្នុងធនាគារ...។ ចំពោះចំណូលទាំងឡាយណាដែលច្បាប់មិនទាន់តម្រូវឱ្យបង់ពន្ធ ក៏អាចត្រូវប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល។

67. សំ. ឡានដែលលក់ឱ្យយើង តែមិនទាន់កាត់ឈ្មោះពីម្ចាស់ដើម តើត្រូវប្រកាសដែរឬទេ?

ចំ. ឡាននេះត្រូវប្រកាសទោះបីមិនទាន់កាត់ឈ្មោះពីម្ចាស់ដើមក៏ដោយ តែយើងយកមកឯកសារទិញលក់រវាងភាគីទាំងពីរមកជាសំអាង ហើយឡាននេះត្រូវបានប្រើប្រាស់ និងគ្រប់គ្រងដោយខ្លួនយើងផ្ទាល់។ ក្នុងន័យមួយទៀត បើឡាននេះបង្កគ្រោះថ្នាក់ដល់អ្នកដទៃ សមត្ថកិច្ចប្រាកដជាតាមរកម្ចាស់ដើមជាមុន តែបើត្រូវបានគេដឹងថាឡាននេះមានឯកសារទិញលក់ឱ្យយើងរួចហើយ យើងនឹងទទួលខុសត្រូវចំពោះការបង្កហេតុដោយឡាននេះ។

68. សំ. តើផ្ទះដែលទិញដោយប្រាក់របស់ប្រពន្ធ តែក្នុងប្លង់LMAP មានឈ្មោះទាំងពីរនាក់ប្តីប្រពន្ធ តើប្តីត្រូវប្រកាសដែរឬទេ?

ចំ. ទោះបីជាលុយរបស់ប្រពន្ធក៏ដោយ ក៏ប្តីត្រូវប្រកាសដែរ ព្រោះមានឈ្មោះប្តីជាសហកម្មសិទ្ធិក្នុងប្លង់នេះ។ បើមិនប្រកាសក្នុងករណីដែលមានការចោទប្រកាន់ថាយើងមិនបានអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុលបានត្រឹមត្រូវ នោះយើងនឹងទទួលរងនូវទោសទណ្ឌ។



វ៉ាអេងឯកសារ

69. សំ. នៅពេលផ្តល់សេវារួចហើយ អតិថិជនបានផ្តល់កម្រៃជូន តើករណីនេះជាអំពើពុករលួយដែរឬទេ?

ចំ. មិនមែនជាអំពើពុករលួយទេ បើកម្រៃខាងលើផ្តល់ជូនដល់ក្រសួង ស្ថាប័ន តែបើផ្តល់ឱ្យមន្ត្រីមានសមត្ថកិច្ចណាមួយ ពិតជាអំពើពុករលួយ។

70. សំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលខុសពីការពិតជាវិធីសាស្ត្រសម្រាប់បើកផ្លូវឱ្យមានអំពើពុករលួយ តើធ្វើយ៉ាងណាទើបយើងអាចដឹងថាមានការប្រកាសខុសដូចខាងលើ?

ចំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលជាវិធានការមួយក្នុងចំណោមវិធានការទាំងឡាយក្នុងការប្រឆាំងនឹងអំពើពុករលួយ។ ការប្រកាសខុសពីការពិត អង្គភាពប្រឆាំងអំពើពុករលួយមិនអាចដឹងថាមានករណីនេះទេ ព្រោះយើងអាចបើកប្រអប់សំបុត្រប្រកាសទ្រព្យសម្បត្តិនិងបំណុលណាមួយ តែក្នុងករណីចាំបាច់នៃការស៊ើបអង្កេតប៉ុណ្ណោះ។

71. សំ. ដីឈ្មោះឪពុកម្តាយក្មេក គ្មានឈ្មោះយើង តើត្រូវប្រកាស ឬមិនប្រកាស? ហើយប្រកាសនៅពេលក្រោយបន្ទាប់ពីមានការផ្ទេរឈ្មោះមកយើងត្រូវបញ្ជាក់ពីប្រភពយ៉ាងដូចម្តេច?

ចំ. បើគ្មានឈ្មោះយើងទេ មានតែឈ្មោះឪពុកម្តាយក្មេក មិនតម្រូវឱ្យប្រកាសទេ។ បើថ្ងៃក្រោយមានការផ្ទេរឈ្មោះមកយើងត្រូវបញ្ជាក់ថា ដីនេះបានពីឪពុកម្តាយក្មេក។

72. សំ. ប្រាក់ខែរបស់មន្ត្រីរាជការតែ ១០ម៉ឺន ទៅ ២០ម៉ឺន តើមានជាប់ប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. ទោះបីមិនទទួល ឬទទួលបានប្រាក់ខែក្នុងកម្រិតណាក៏ដោយ បើបុគ្គលនោះត្រូវកំណត់ដោយច្បាប់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល គឺត្រូវប្រកាសជាដាច់ខាត។ ឧទាហរណ៍ ទីប្រឹក្សា ឬជំនួយការថ្នាក់ដឹកនាំដែលមិនទទួលប្រាក់បៀវត្ស និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាដើម។

73. សំ. តើបុគ្គលចំនួនប៉ុន្មានរូប អាចប្តឹងដើម្បីឱ្យអង្គភាពប្រឆាំងអំពើពុករលួយ ចុះស៊ើបអង្កេតអំពីពុករលួយបាន?

ចំ. សូម្បីតែមួយរូបក៏ស៊ើបអង្កេតបាន ហើយអង្គភាពប្រឆាំងអំពើពុករលួយមានកាតព្វកិច្ចការពារសុវត្ថិភាពចំពោះប្រភពនេះ។ តែបើអ្នកប្តឹងមានចំនួនច្រើនផ្តល់ផលប្រយោជន៍ខ្ពស់ធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចរបស់ស្ថាប័នតុលាការ។

74. សំ. ការសុំលុយសម្រាប់ដោះស្រាយនៅក្នុងអង្គភាពសាធារណៈ តើ ចាត់ទុកជាទង្វើខុសច្បាប់ដែរ ឬទេ?

ចំ. ករណីច្បាប់អនុញ្ញាតមិនមែនជាទង្វើខុសច្បាប់ទេ ប៉ុន្តែបើច្បាប់មិនអនុញ្ញាតឱ្យសុំ ឬទទួល វាជាទង្វើខុសច្បាប់។

75. សំ. តើគណៈកម្មការបេក្ខនៅតាមក្រសួង ស្ថាប័ននីមួយៗមានវិសមិតភាពជាមួយក្រុមជនបង្គោលដែរឬទេ?

ចំ. ជនបង្គោលអាចធ្វើជាគណៈកម្មការបេក្សនៅតាមក្រសួង ស្ថាប័ននីមួយៗបាន ព្រោះការងារទាំងពីរនេះដាច់ដោយឡែកពីគ្នា ហើយកុំឱ្យតែមានទំនាស់ផលប្រយោជន៍។

76. សំ. អ្នកទទួលបន្ទុកខាងហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ននីមួយៗ តើមានទំនាស់ផល



វ៉ាំងឯកសារ

ប្រយោជន៍ជាមួយក្រុមជនបង្គោលដែរឬទេ?

ចំ. អ្នកកាន់ហ៊ុនក្រុមហ៊ុនមិនមានទំនាស់ផលប្រយោជន៍ជាមួយក្រុមជនបង្គោលទេ។ មានន័យថាអ្នកទាំងនេះអាចធ្វើជាក្រុមជនបង្គោលបាន។

77. សំ. បុគ្គលមួយមានចិញ្ចៀន ២០វង់ ក្នុងមួយវង់តម្លៃ ៥០០$ តើត្រូវប្រកាសដែរឬទេ?

ចំ. ករណីនេះមិនប្រកាសទេ ប្រសិនចិញ្ចៀនមួយវង់តម្លៃត្រឹមតែ ៥០០ ដុល្លារ តែបើថ្លៃក្រោយចិញ្ចៀនទាំងនេះបញ្ចូលគ្នាតែមួយវង់ដែលមានតម្លៃលើសពី ៤លានរៀល គឺត្រូវប្រកាស។

78. សំ. មន្ត្រីរាជការដែលមិនមកបម្រើការ តែទទួលប្រាក់ខែរាល់ខែ តើជាអំពើពុករលួយដែរឬទេ?

ចំ. ករណីដែលមិនមកធ្វើការជាថ្នូរនឹងការផ្តល់ប្រាក់ដល់ថ្នាក់លើរបស់ខ្លួន ជាអំពើពុករលួយ។ ចំណែកឯការមិនមកធ្វើការ និងបែរជាទទួលបានប្រាក់ខែជាធម្មតាក៏ជាអំពើពុករលួយផងដែរ។

79. សំ. តើការប្រឡងយកលុយចាត់ទុកថាជាអំពើពុករលួយដែរឬទេ?

ចំ. មិនមានច្បាប់ណាមួយដែលតម្រូវឱ្យទទួល ផ្តល់ឱ្យ សុំលុយនៅពេលមានការប្រឡងនោះទេ។ បើការប្រឡងមានការយកលុយ វាពិតណាស់ថាជាអំពើពុករលួយ។

80. សំ. តើមន្ត្រីរាជការនៃក្រសួងធម្មការ និងសាសនា មានវិសមិតភាពជាមួយនឹងការបំពេញការងារអ្វីខ្លះ?

ចំ. ករណីនេះ ក្រុមជនបង្គោលរបស់ក្រសួងធម្មការ និងសាសនា ជាអ្នកកំណត់។ ឧទាហរណ៍ តើមន្ត្រីរាជការនៃក្រសួងនេះអាចបំពេញតួនាទីជាអាចារ្យតាមវត្តអារាមបានដែរឬទេ? ក្រុមជនបង្គោលជាអ្នកកំណត់ថា តើការងារប្រភេទណា ដែលមន្ត្រីរាជការនៃក្រសួងនេះអាចបំពេញបាន និង តើការងារប្រភេទណាខ្លះទៀត ដែលមិនអាចបំពេញបាន។

81. សំ. តើសាច់ប្រាក់ចំនួន ២០លានរៀល តម្រូវឱ្យប្រកាសដែរឬទេ?

ចំ. សាមីខ្លួនអាចប្រកាសក៏បាន និងមិនប្រកាសក៏បាន។ ការប្រកាសសាច់ប្រាក់នេះច្បាប់មិនតម្រូវឱ្យប្រកាសជាចាំបាច់ទេ វាជាករណីស្ម័គ្រចិត្តរបស់បុគ្គលនីមួយៗ។

82. សំ. តើមន្ត្រីអធិការកិច្ច និងសវនកម្ម នៃក្រសួង ស្ថាប័ន អាចជាក្រុមជនបង្គោលបានដែរឬទេ?

ចំ. មន្ត្រីទាំងនេះអាចបម្រើការជាក្រុមជនបង្គោលបាន។ ប្រធានក្រសួង ស្ថាប័ននីមួយៗមានសិទ្ធិគ្រប់គ្រាន់ក្នុងការកំណត់យកបុគ្គលណាមួយឱ្យបម្រើការជាក្រុមជនបង្គោលបាន និង ទទួលនូវទំនុកចិត្ត ព្រមទាំងមិនមានទំនាស់ផលប្រយោជន៍។

83. សំ. មន្ត្រីរាជការមួយរូបដែលបើកប្រាក់ខែពីរកន្លែងផ្សេងគ្នា តើជាអំពើពុករលួយដែរឬទេ?

ចំ. វាពិតជាអំពើពុករលួយ។ បុគ្គលមួយរូបអាចបើកប្រាក់ខែតែមួយកន្លែង។

84. សំ. មុខងារជាមន្ត្រីនៅក្រសួង ស្ថាប័នមួយ តើអាចធ្វើជាប្រធានមូលនិធិណាមួយបានដែរឬទេ?

ចំ. មន្ត្រីរាជការអាចធ្វើជាប្រធានមូលនិធិបាន។ មិនមានច្បាប់ណាមួយឃាត់មិនឱ្យធ្វើ។

85. សំ. លេខទូរស័ព្ទដែលមានឈ្មោះយើងជាអ្នកទិញ តែត្រូវបានឈប់ប្រើប្រាស់ តើត្រូវប្រកាសដែរឬទេ?

ចំ. មិនទាមទារឱ្យប្រកាសទេ ព្រោះលេខទូរស័ព្ទនេះមិនបានប្រើប្រាស់ យើងប្រកាសតែលេខទូរស័ព្ទណាដែលកំពុងប្រើប្រាស់តែប៉ុណ្ណោះ។

86. សំ. ព្រះសង្ឃដែលមានទ្រព្យជាទ្រព្យសាធារណៈ តើត្រូវប្រកាសទ្រព្យសម្បត្តិទាំងនោះដែរឬទេ?
ចំ. ទ្រព្យសម្បត្តិសាធារណៈដូចជាវត្តអារាម មិនតម្រូវឱ្យព្រះសង្ឃប្រកាសទេ។
87. សំ. អំណោយប្រគេនព្រះសង្ឃ តើអាចចាត់ទុកជាអំពើពុករលួយដែរឬទេ?
ចំ. អំណោយប្រភេទនេះមិនមែនជាអំពើពុករលួយទេ ព្រោះមិនមានការផ្តល់មកវិញជាផ្នូរនឹងផលប្រយោជន៍អ្វីឡើយ។
88. សំ. មន្ត្រីរាជការតំណាងឱ្យរដ្ឋ ជាម្ចាស់អចលនទ្រព្យ តើត្រូវប្រកាសអចលនទ្រព្យនោះដែរឬទេ?
ចំ. អចលនទ្រព្យនេះមិនមែនជាទ្រព្យសម្បត្តិផ្ទាល់របស់បុគ្គលនោះទេ ដូច្នេះមិនតម្រូវឱ្យប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ។
89. សំ. ប្រធាននាយកដ្ឋាននៅតាមស្ថាប័នសាធារណៈ ដែលមិនតែងតាំងដោយអនុក្រឹត្យ តើត្រូវប្រកាសដែរឬទេ?
ចំ. បុគ្គលនេះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ព្រោះគាត់មានបៀវត្ស និងបុព្វសិទ្ធិដូចប្រធាននាយកដ្ឋាននៅតាមក្រសួង ស្ថាប័នដទៃទៀតដែរ។
90. សំ. ឡាន ឬលេខទូរស័ព្ទដែលប្រើប្រាស់អត្តសញ្ញាណប័ណ្ណរបស់យើង តែយើងមិនបាននិងកំពុងប្រើប្រាស់ទេ តើត្រូវប្រកាសដែរឬទេ?
ចំ. ករណីនេះយើងមិនចាំបាច់ប្រកាសទេ។ យើងប្រកាសតែឡាន ឬលេខទូរស័ព្ទដែលកំពុងប្រើប្រាស់តែប៉ុណ្ណោះ។
91. សំ. ២០ឆ្នាំមុន តម្លៃតិចជាង៥លាន ឥឡូវលើសពី៩លាន សម្រាប់អចលនទ្រព្យ តើត្រូវប្រកាសដែរឬទេ?
ចំ. ទោះក្នុងតម្លៃណាក៏ដោយឱ្យតែជាប្រភេទអចលនទ្រព្យត្រូវប្រកាសជាដាច់ខាត។
92. សំ. តើចំណូលបានមកពីកម្រៃជើងសារ (គុកជេរ) ជាចំណូលស្របច្បាប់ដែរឬទេ?
ចំ. ចំណូលប្រភេទនេះជាចំណូលស្របច្បាប់ ឱ្យតែចំណូលនេះមានប្រភពមកពីសកម្មភាពស្របច្បាប់។
93. សំ. តើចំណូលដែលបានមកពីការលេងតុងទីន និងចំណូលពីការប្រាក់ ត្រូវប្រកាសដែរឬទេ? ហើយចំណូលទាំងពីរនេះមានការបង់ពន្ធឬយ៉ាងណា?
ចំ. ចំណូលទាំងនេះប្រកាសក៏បាន មិនប្រកាសក៏បាន។ ឯការយកពន្ធលើចំណូលទាំងនេះវាជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
94. សំ. តើព័ត៌មានស្តីពីកូន ចុះតែកូននៅក្នុងបន្ទុកឬយ៉ាងណា?
ចំ. ទោះកូនក្នុងបន្ទុកក្តីឬក្រៅបន្ទុកក្តី មានគ្រួសារក្តីឬគ្មានគ្រួសារក្តី ក្នុងស្រុកក្តីឬនៅបរទេសក្តី កូនបង្កើតក្តីឬកូនចិញ្ចឹមក្តី គ្រប់កម្រិតអាយុទាំងអស់ ត្រូវតែចុះក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទាំងអស់។ កូនធម៌មិនតម្រូវឱ្យប្រកាសក្នុងឯកសារនេះទេ។
95. សំ. តើក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានសិទ្ធិអំណាច និងភារកិច្ចអ្វីខ្លះក្នុងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ?
ចំ. ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានកំណត់ក្នុងមាត្រា ១០ នៃច្បាប់ស្តីពីការ

ប្រឆាំងអំពើពុករលួយ។ ជាអាទិ៍ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាចលើកសំណើផ្លាស់ប្តូរថ្នាក់ដឹកនាំអង្គភាពប្រឆាំងអំពើពុករលួយ និងធ្វើរបាយការណ៍អំពីដំណើរការរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជូននាយករដ្ឋមន្ត្រី។ យោបល់ និងអនុសាសន៍របស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមិនមែនជាការសម្រេចដាច់ខាត និងស្ថាពរនោះទេ។

96. សំ. តើអ្នកចូលនិវត្តត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២ដែរឬទេ?

ចំ. បុគ្គលនេះមិនប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២ទេ បើបុគ្គលនេះចូលនិវត្តមុនកាលបរិច្ឆេទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២នោះ។

97. សំ. តើចំណូលដែលទទួលបានមិនទៀងទាត់ ប្រកាសយ៉ាងដូចម្តេច?

ចំ. ចំណូលប្រភេទនេះ យើងអាចប្រកាសជាលក្ខណៈប៉ាន់ស្មានបាន និងយកទិន្នន័យពីឆ្នាំមុនមកធ្វើការប្រកាស។

98. សំ. លុយបានមកពីប្រឹក្សាយោបល់ តើត្រូវប្រកាស ឬមិនប្រកាស?

ចំ. លុយប្រភេទនេះត្រូវប្រកាសក្នុងចំណុចសាច់ប្រាក់។

99. សំ. តើភារកិច្ចរបស់ក្រុមជនបង្គោលនៅតាមក្រសួង ស្ថាប័នមានអ្វីខ្លះ?

ចំ. ភារកិច្ចទាំងមាន១០ចំណុចរបស់ក្រុមជនបង្គោលគឺ៖

- ទំនាក់ទំនង និងសហការដោយផ្ទាល់ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយប្រចាំ (ក្រសួង ស្ថាប័ន)។

- ទទួលបន្ទុកពលកម្មការងារពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដូចជាធ្វើបញ្ជីឈ្មោះអ្នកត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុង (ក្រសួង ស្ថាប័ន) រួចបញ្ជូនមកអង្គភាពប្រឆាំងអំពើពុករលួយ។ ផ្សព្វផ្សាយគោលការណ៍ណែនាំអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល និងរៀបចំបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទាំងអស់មកអង្គភាពប្រឆាំងអំពើពុករលួយ។

- តាក់តែង និងឆ្លង (រដ្ឋមន្ត្រី ប្រធាន) នូវក្រមសីលធម៌ផ្ទៃក្នុង (ក្រសួង ស្ថាប័ន) រួចបញ្ជូនមកអង្គភាពប្រឆាំងអំពើពុករលួយ។

- (១). រៀបចំ និងឆ្លង (រដ្ឋមន្ត្រី ប្រធាន) នូវផែនការសកម្មភាពប្រឆាំងអំពើពុករលួយរបស់ (ក្រសួង ស្ថាប័ន) (២). ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពនេះ (៣). ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារអនុវត្តផែនការសកម្មភាពនេះ ដើម្បីដាក់ជូនអង្គភាពប្រឆាំងអំពើពុករលួយ (៤). ចូលរួមប្រជុំបូកសរុបលទ្ធផលការងារអនុវត្តផែនការសកម្មភាពនេះ ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ និង (៥). ទទួល និងអនុវត្តតាមការណែនាំបន្ថែមនានាទាក់ទងនឹងផែនការសកម្មភាពនេះ ពីអង្គភាពប្រឆាំងអំពើពុករលួយប្រសិនបើមាន។

- (១). ដឹកនាំ កសាងអង្គភាពសស្អាត និងមនុស្សល្អ ការងារល្អ សុចរិត (គ្មានអំពើពុករលួយ) និងក្នុង (ក្រសួង ស្ថាប័ន) (២). ផ្សព្វផ្សាយ និងណែនាំអំពីគោលការណ៍អភិបាលកិច្ចល្អ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ (ក្រសួង ស្ថាប័ន) និង (៣). ជំរុញឱ្យមានការបង្កើត

និងអនុវត្តនូវគោលនយោបាយចាំបាច់នានា ទាក់ទងនឹងអភិបាលកិច្ចល្អ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ (ក្រសួង ស្ថាប័ន)។

- (១). រៀបចំបទបញ្ញត្តិអំពីការទទួលអំណោយសម្រាប់ (ក្រសួង ស្ថាប័ន) និង (២). ធ្វើរបាយការណ៍ប្រចាំខែអំពីអំណោយ និងមន្ត្រីដែលទទួលអំណោយ ការសម្រេចរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយទៅលើអំណោយនោះមកអង្គភាពប្រឆាំងអំពើពុករលួយ។

- (១). រៀបចំទម្រង់ប្រកាសទំនាស់ផលប្រយោជន៍ដែលមាន និងអាចមានសម្រាប់ (ក្រសួង ស្ថាប័ន) និង (២). ធ្វើរបាយការណ៍ប្រចាំខែអំពីការប្រកាសទំនាស់ផលប្រយោជន៍ដែលមាន និងអាចមាននៅក្នុង (ក្រសួង ស្ថាប័ន) មកអង្គភាពប្រឆាំងអំពើពុករលួយ។

- ផ្តល់កិច្ចសហការ ក្នុងដំណើរការផ្តល់ចំណាត់ថ្នាក់ និងវង្វាន់សុចរិតភាពប្រចាំឆ្នាំដល់ (ក្រសួង ស្ថាប័ន)។

- (១). ផ្តល់ព័ត៌មាន និងកិច្ចសហការជាមួយក្រុមសិក្សាស្រាវជ្រាវរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីលុបបំបាត់លទ្ធភាព និងឱកាសប្រព្រឹត្តអំពើពុករលួយនៅក្នុង (ក្រសួង ស្ថាប័ន) និង (២). ជំរុញឱ្យមានការផ្លាស់ប្តូរដែលចាំបាច់ក្នុងផ្នែកដែលមានហានិភ័យខ្ពស់នៅក្នុង (ក្រសួង ស្ថាប័ន)។

- ចូលរួមការបណ្តុះបណ្តាលតាមការអញ្ជើញរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងផ្តល់ការគាំទ្រចាំបាច់នានាដែលមានដល់អង្គភាពប្រឆាំងអំពើពុករលួយ។

100. សំ. បើមិនមានឯកសារបញ្ជាក់ជាក់លាក់ណាមួយលើតម្លៃគ្រឿងអលង្ការ តើត្រូវដាក់យ៉ាងណា?

ចំ. បើតម្លៃនៅពេលទទួលបានគ្រឿងអលង្ការនោះចាប់ពី ៥លានរៀល ត្រូវប្រកាស បើមិនមានឯកសារបញ្ជាក់ ឬមិនចាំតម្លៃច្បាស់លាស់ ត្រូវដាក់ក្នុងតម្លៃប៉ាន់ស្មាន។

101. សំ. មន្ត្រីចូលនិវត្តត្រូវប្រកាសដំបូង និងប្រកាសមុន ឬក្រោយចូលនិវត្ត តើACU យកឯកសារទាំងពីរមកផ្ទៀងផ្ទាត់ឬទេ?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយមិនមានសិទ្ធិយកឯកសារទាំងនេះមកផ្ទៀងផ្ទាត់ឡើយ ។ ឯកសារទាំងនេះអាចពិនិត្យតែក្នុងករណីចាំបាច់នៃស៊ើបអង្កេតអំពើពុករលួយតែប៉ុណ្ណោះ។

102. សំ. ដីក្នុងសហគមន៍ជនជាតិភាគតិច តើត្រូវប្រកាសដែរឬទេ? ហើយតម្លៃដាក់យ៉ាងដូចម្តេច?

ចំ. ដីប្រភេទនេះត្រូវប្រកាស គ្រាន់តែបញ្ជាក់ថាជាដីរបស់សហគមន៍។ ចំពោះតម្លៃបញ្ជាក់ក៏បានក្នុងករណីដឹង ឬមិនបញ្ជាក់ក៏បានក្នុងករណីមិនដឹង។

103. សំ. ដីដែលទិញលក់មានការទទួលស្គាល់ និងហត្ថលេខាដោយមេឃុំ ឬអភិបាលស្រុក តែជាដីដែលស្ថិតក្នុងទ្រព្យសម្បត្តិរបស់រដ្ឋ តើតម្រូវឱ្យប្រកាសដែរឬទេ?

ចំ. ទោះបីជាទ្រព្យសម្បត្តិរដ្ឋក៏ដោយ ដូចគ្នានឹងករណីដីកំពុងមានទំនាស់នៅតុលាការ ត្រូវប្រកាសជាដាច់ខាត។

104. សំ. គ្រឿងអលង្ការដែលរក្សាទុកនៅប្រពន្ធ ហើយបានពាក់ម្តងម្កាល តើត្រូវប្រកាសដែរឬទេ?

ចំ. ប្រពន្ធគ្រាន់តែជាអ្នករក្សាទុកទ្រព្យទាំងនោះទេ តែសាមីខ្លួន(ប្តី)ជាម្ចាស់ពិតប្រាកដនៃ

ទ្រព្យផ្ទះត្រូវប្រកាសជាធម្មតា។

105. សំ. ដីមួយកន្លែងជាដីសហកម្មសិទ្ធិរបស់បុគ្គល A និង B , បុគ្គល B មានផ្ទះ តើត្រូវប្រកាសយ៉ាងណា?

ចំ. ការប្រកាសអំពីដីនេះត្រូវអនុវត្តតាមការលើកឡើងខាងលើ។ បុគ្គល A និង B ជាសហកម្មសិទ្ធិនៃដី។ មានតែបុគ្គល B ជាម្ចាស់កម្មសិទ្ធិលើផ្ទះ។

106. សំ. លេខទូរស័ព្ទដែលនឹងត្រូវប្រើថ្ងៃក្រោយ ក្រោយការប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកដំបូង តើត្រូវប្រកាសយ៉ាងដូចម្តេច?

ចំ. សាមីខ្លួនប្រកាសលេខទូរស័ព្ទណាដែលកំពុងប្រើប្រាស់។ លេខទូរស័ព្ទដែលប្រើប្រាស់ក្រោយការប្រកាសលើកដំបូង ត្រូវប្រកាសពេលប្រកាសលើកក្រោយ។

107. សំ. មន្ត្រីដែលជាទីប្រឹក្សា និងជំនួយការអមអគ្គលេខាធិការដ្ឋានរដ្ឋសភាមិនបានតែងតាំងដោយអនុក្រឹត្យ ឬព្រះរាជក្រឹត្យទេ គ្មានឋានៈស្មើអ្វី តែទទួលបៀវត្សស្មើនឹងឋានៈរដ្ឋលេខាធិការប្រមាណ ២លានរៀល ក្នុងមួយខែ តើត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. មន្ត្រីជាទីប្រឹក្សា ឬជំនួយការអមអគ្គលេខាធិការដ្ឋានរដ្ឋសភាដែលតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា តែ ទទួលបៀវត្សពីរដ្ឋរហូតដល់ ២លានរៀល ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល។

108. សំ. តើមេធាវីអាចត្រូវបានចោទប្រកាន់ និងជាប់ទោសពីបទល្មើសពុករលួយដែរឬទេ?

ចំ. បុគ្គលណាក៏ដោយឱ្យតែប្រព្រឹត្តបទល្មើសណាមួយឱ្យតែមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ទោះជាបុគ្គលនោះជាមេធាវីក្តីក៏ត្រូវទទួលរងនូវការចោទប្រកាន់ និងទណ្ឌកម្មនៃបទល្មើសពុករលួយ។

109. សំ. តើមានច្បាប់ណាផ្សេងទៀតដែលអាចយកមកអនុវត្តចំពោះបទល្មើសពុករលួយបាន នៅពេលដែលច្បាប់ព្រហ្មទណ្ឌអន្តរកាលលែងមានអានុភាពអនុវត្ត?

ចំ. ច្បាប់ព្រហ្មទណ្ឌអន្តរកាលនៅតែបន្តអានុភាពអនុវត្តដរាបណាបញ្ញត្តិនៃបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមិនទាន់ត្រូវបានចូលជាធរមាន។

110. សំ. តើការដឹងគុណចំពោះអ្នកណាម្នាក់ ឬការជូនជាសារគុណទៅអ្នកណាម្នាក់អាចចាត់ទុកជាអំពើពុករលួយដែរ ឬទេ?

ចំ. ករណីនេះមិនមែនជាអំពើពុករលួយទេ កាលណាមិនមានអត្ថប្រយោជន៍តបស្នងមកវិញ។

111. សំ. នៅពេលមានការផ្លាស់ប្តូរ ឬលក់អចលនទ្រព្យដែលបានប្រកាសរួច តើគួរធ្វើរបៀបណា?

ចំ. សាមីខ្លួនត្រូវប្រកាសតាមការជាក់ស្តែងអំពីការផ្លាស់ប្តូរ ឬលក់ទ្រព្យសម្បត្តិទាំងនោះនៅពេលប្រកាសបន្ទាប់ទៀត។

112. សំ. ទាក់ទងនឹងមាត្រា២៥ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ តើទាំងតំណាងអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ដទៃទៀត អាចបញ្ជូនសំណុំរឿងបទល្មើសពុករលួយទៅអង្គភាពប្រឆាំងអំពើពុករលួយ?

https://www.facebook.com/Voangeksa

ចំ. អាចបញ្ជូន។ ច្បាប់តម្រូវឱ្យអង្គភាពទាំងឡាយដែលដឹងពីហេតុការណ៍នៃរឿងពុករលួយត្រូវរាយការណ៍ជូនអង្គភាព ឬការិយាល័យប្រឆាំងអំពើពុករលួយរាជធានី-ខេត្ត។

113. សំ. បញ្ហាអចលនទ្រព្យអត់មានប័ណ្ណកម្មសិទ្ធិ ត្រូវប្រកាសដូចម្តេច? ករណីនៅទីក្រុងភ្នំពេញ ផ្ទះល្វែង$E_0$ខ្លះមានកម្មសិទ្ធិ តែចំពោះ$E_1$ និង $E_2$ អត់មានកម្មសិទ្ធិ តើប្រកាសដូចម្តេច?

ចំ. ត្រូវប្រកាសជាធម្មតា តែបញ្ជាក់ថាមិនទាន់មានប្លង់រឹង។

114. សំ. អចលនវត្ថុ (ដីធ្លី) ទិញនៅខេត្តឆ្ងាយ ហើយដាក់ឈ្មោះបងប្អូនដែលស្នាក់នៅតំបន់នោះ តើយើងគួរប្រកាសដូចម្តេច?

ចំ. សាមីខ្លួនប្រកាសដីធ្លីទាំងឡាយណាដែលមានឈ្មោះផ្ទាល់របស់ខ្លួន បើឈ្មោះរបស់អ្នកដទៃមិនប្រកាសទេ ទោះបីខ្លួនជាចំណាយប្រាក់ដើម្បីទទួលបាននូវដីធ្លីនេះក៏ដោយ។

115. សំ. តើខ្លឹមសារនៃមាត្រា២០ និងមាត្រា៣៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមានលក្ខណៈទាក់ទងគ្នាដូចម្តេចដែរ?

ចំ. មាត្រា ២០ បានចែងថាឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវរក្សាទុកជាការសម្ងាត់ខ្ពស់បំផុត ចំណែកឯមាត្រា ៣៩ បានចែងថាបុគ្គលណាដែលធ្វើឱ្យធ្លាយនូវប្រភពព័ត៌មានស្តីអំពីអំពើពុករលួយនឹងត្រូវបានផ្តន្ទាទោស។

116. សំ. តើមន្ត្រីរាជការយកម៉ោងការងារទៅបម្រើការងារឯកជន ជាប់ពីបទពុករលួយដែរ ឬទេ?

ចំ. ក្រុមជនបង្គោលជាអ្នកកំណត់ថាជាអំពើពុករលួយ ឬមិនពុករលួយ។

117. សំ. គ្រូបង្រៀនដែលយកសាលារៀន និងម៉ោងរដ្ឋទៅបង្រៀនក្រៅម៉ោង តើជាអំពើពុករលួយដែរឬទេ?

ចំ. ក្រុមជនបង្គោលជាអ្នកកំណត់ថាជាអំពើពុករលួយ ឬមិនពុករលួយ។

118. សំ. ការប្រកាសទ្រព្យសម្បត្តិលើកដំបូង មិនបញ្ជាក់ពីប្រភព តើមូលហេតុអ្វីបានជាមិនឱ្យបញ្ជាក់?

ចំ. មូលហេតុទី១៖ គឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ច្បាប់នេះមិនបានគ្របដណ្តប់លើសកម្មភាព ឬទ្រព្យសម្បត្តិទាំងឡាយណាដែលកើតមានមុនការប្រកាសឱ្យប្រើនៃច្បាប់នេះ។

មូលហេតុទី២៖ គឺខ្លឹមសារនៃមាត្រា៣៦ នៃច្បាប់ស្តីពីការការប្រឆាំងអំពើពុករលួយដែលចែងអំពីការមានទ្រព្យសម្បត្តិដោយខុសច្បាប់ ។ មានកំណើននៃទ្រព្យសម្បត្តិខុសច្បាប់លុះត្រាតែមានការចាប់ផ្តើមណាមួយ។ បើប្រកាសលើកដំបូងនេះតម្រូវឱ្យបញ្ជាក់ពីប្រភពហិរញ្ញប្បទានគឺមិនមានមូលដ្ឋានណាមួយសម្រាប់គិតគូរ ព្រោះយើងមិនធ្លាប់បានប្រកាស។

មូលហេតុទី៣៖ គឺកត្តានយោបាយដែលសារមួយបញ្ជាក់ថារាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងទទួលស្គាល់នូវទ្រព្យសម្បត្តិរបស់បុគ្គលគ្រប់រូបដែលកើតមានការប្រកាសឱ្យប្រើនៃច្បាប់

ស្តីពីការប្រឆាំងអំពើពុករលួយ។

119. សំ. តើប្រធានមន្ទីរតាមបណ្តារាជធានី ខេត្ត តម្រូវឱ្យប្រកាសដែរឬទេ?

ចំ. ក្នុងដំណាក់ដំបូងនេះមន្ត្រីរាជការដែលត្រូវបានតែងតាំងដោយប្រកាសមិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ។ ប្រធានមន្ទីរ ក៏ដូចជាមន្ត្រីឯទៀតដែលតែងតាំងដោយប្រកាសនឹងអាចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលពេលក្រោយ បន្ទាប់ពីអង្គភាពប្រឆាំងអំពើពុករលួយបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។

120. សំ. ការរកស៊ីដែលប្រពន្ធជាអ្នកគ្រប់គ្រង និងឈរឈ្មោះ តើប្តីត្រូវប្រកាសពីចំណូលនៃការរកស៊ីនេះដូចម្តេច?

ចំ. ករណីនេះប្តីមិនចាំបាច់ប្រកាសពីចំណូលដែលបានមកពីការរកស៊ីនេះទេ។ ចំណូលនេះជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

121. សំ. តើយើងអាចផ្តិតមេដៃពណ៌អ្វីខ្លះនៅលើទម្រង់ប្រកាសទ្រព្យសម្បត្តិ?

ចំ. សាមីខ្លួនអាចផ្តិតមេដៃជាពណ៌ខៀវ ឬក្រហមតែប៉ុណ្ណោះ។

122. សំ. តើទម្រង់ប្រកាសទ្រព្យសម្បត្តិ និងបំណុល អាចវាយកុំព្យូទ័រឡើងវិញបានឬទេ?

ចំ. សាមីខ្លួនអាចវាយជាកុំព្យូទ័រនូវឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តែត្រូវធានាឱ្យបាននូវទម្រង់ និងខ្លឹមសារដើមដែលផ្តល់ជូនដោយអង្គភាពប្រឆាំងអំពើពុករលួយ។

123. សំ. តើយើងអាចផ្តិតមេដៃនៅគ្រប់ទំព័រទាំងអស់នៃខ្លឹមសារខាងក្នុងនៃទម្រង់ប្រកាសទ្រព្យសម្បត្តិ និងបំណុលបានដែរឬទេ?

ចំ. បុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុលអាចផ្តិតមេដៃបាននៅគ្រប់ទំព័រនៃឯកសារខាងក្នុង ដើម្បីធានាឱ្យបាននូវការទុកចិត្ត និងសិទ្ធិសេរីភាពរបស់បុគ្គល។

124. សំ. នាឡិកាមួយគ្រឿងមានតម្លៃតែ ៣,២លានរៀល តើត្រូវប្រកាសដែរឬទេ?

ចំ. មិនថាឡើយនាឡិកាមួយគ្រឿងតម្លៃ ៣,២ លានរៀល បើនាឡិកាមួយគ្រឿងនេះមានតម្លៃមិនគ្រប់ ៤លានរៀល មិនតម្រូវឱ្យប្រកាសទេ។

125. សំ. តើមន្ត្រីរាជការក្រសួងពាណិជ្ជកម្មអាចប្រកបមុខរបរជាលក្ខណៈពាណិជ្ជកម្ម ឬលក់ចាប់ហួយបានដែរឬទេ?

ចំ. គ្រូពេទ្យអាចបើកគ្លីនិកឯកជនផ្ទាល់ខ្លួនបាន។ គ្រូបង្រៀនអាចបើកសាលាឯកជន។ មន្ត្រីរាជការនៃក្រសួងកសិកម្មអាចធ្វើស្រែចម្ការ និងមុខរបរកសិកម្មដទៃទៀត។ មន្ត្រីគយមានវិសមិតភាពចំពោះសេវាកម្មនីហរណ៍ អាហរណ៍។ ដូច្នេះក្រុមជនបង្គោលនៃក្រសួងពាណិជ្ជកម្មនឹងកំណត់ថាមុខរបរអ្វីខ្លះដែលមន្ត្រីរាជការនៃក្រសួងរបស់ខ្លួនធ្វើបាន ឬមិនអាចធ្វើបាន និងធានាបានថាមុខរបរទាំងនោះមិនមានទំនាស់ផលប្រយោជន៍ជាមួយនឹង



វាំងឯកសារ

ការបំពេញមុខងារជាមន្ត្រីរាជការ។

126. សំ. ដី និងផ្ទះទិញនៅឆ្នាំ ១៩៩៧ ក្នុងតម្លៃ ៧តម្លឹង ហើយនៅឆ្នាំ២០០៥ ត្រូវបានជួសជុលឡើងវិញអស់តម្លៃ ១៥ម៉ឺនដុល្លារ តើត្រូវប្រកាសតម្លៃយ៉ាងដូចម្ដេច?

ចំ. ចំពោះតម្លៃត្រូវរាយការណ៍តាមការជាក់ស្ដែងដែលបានរៀបរាប់ខាងលើ។

127. សំ. តើអ្នកស្មុគនៃបទល្មើសពុករលួយដែលមករាយការណ៍ជូនអង្គភាពប្រឆាំងអំពើពុករលួយ អាចទទួលបានការលើកលែងទោសដែរឬទេ?

ចំ. បើបុគ្គលនោះមិនព្រមផ្ដល់សំណូក តែផ្ដល់ការសហការជាមុនប្រឆាំងអំពើពុករលួយមកអង្គភាពប្រឆាំងអំពើពុករលួយ បុគ្គលនោះនឹងទទួលបានការធានាសុវត្ថិភាព និងមិនត្រូវបានចោទប្រកាន់ពីបទល្មើសពុករលួយនោះទេ។ ផ្ទុយទៅវិញ បើបុគ្គលនោះបានសូករួចទៅហើយនោះ ច្បាប់តម្រូវឱ្យទទួលទោស និងមិនអាចលើកលែងទោសបានទេ។

128. សំ. តើប្រជាពលរដ្ឋអាចមានភារកិច្ចប្រឆាំងអំពើពុករលួយដែរឬទេ?

ចំ. បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមលើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយចាត់វិធានការការពារសុវត្ថិភាពផ្ទាល់ខ្លួនចំពោះប្រភពដែលបានសហការ និងផ្ដល់ព័ត៌មានស្ដីពីសកម្មភាពពាក់ព័ន្ធទៅនឹងអំពើពុករលួយ។

129. សំ. តើការងារគួកជេរដើមានទំនាស់ផលប្រយោជន៍ទៅនឹងមុខងារមន្ត្រីរាជការដែរឬទេ?

ចំ. ចំណូលគួកជេរដី និងផ្ទះ ជាចំណូលស្របច្បាប់ តែការបំពេញការងារគួកជេរនេះមិនត្រូវធ្វើយ៉ាងណាពាក់ព័ន្ធនឹងបទល្មើសជំនួញឥទ្ធិពលអកម្ម។

130. សំ. យោធិនដែលជាប់ដៃនៅសមរភូមិ ដូចករណីកងពលធំអន្តរាគមន៍លេខ៣ សព្វថ្ងៃជាប់រវល់នៅសមរភូមិមុខ តើអាចពន្យារពេលប្រកាសទ្រព្យសម្បត្តិ និងបំណុលបានដែរឬទេ?

ចំ. ច្បាប់តម្រូវឱ្យបុគ្គលគ្រប់រូបគោរព និងអនុវត្ត។ មិនអនុវត្តតែបុគ្គលនេះ លើកលែងបុគ្គលនោះទេ។ បើផ្ដល់ការពន្យារពេលជូនយោធិននៃកងពលធំនេះ ក្រសួង ស្ថាប័នផ្សេងៗទៀតនឹងទាមទារនូវការអនុគ្រោះដូចគ្នានេះដែរ។ អង្គភាពប្រឆាំងអំពើពុករលួយយោគយល់ចំពោះបុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុលទាំងឡាយណាដែលជួបប្រទះនូវការយឺតយ៉ាវដែលបណ្ដាលមកពីការដឹកជញ្ជូន ឬមធ្យោបាយសម្រាប់ការផ្ញើ។

131. សំ. ការទិញឡានមួយជាមួយប្រពន្ធ តែដាក់ឈ្មោះខ្ញុំ តើត្រូវប្រកាសដែរឬទេ?

ចំ. បើមានឈ្មោះយើងផ្ទាល់ ទោះសម្បត្តិនោះជាសម្បត្តិរួមក៏ដោយត្រូវប្រកាសទ្រព្យសម្បត្តិ។ ករណីនេះយើងត្រូវប្រកាសពីឡាននេះ ពីព្រោះមានឈ្មោះយើង។

132. សំ. ចំពោះនាយទាហានទៅរៀននៅក្រៅប្រទេសយូរឆ្នាំ តើអាចមិនប្រកាសទ្រព្យសម្បត្តិ និងបំណុលបានឬទេ?



ភីធីវិកសារ

ចំ. គាត់ត្រូវប្រកាស ដោយមានជំនួយពីក្រុមជនបង្គោល។ ប្រសិនបើគាត់ប្រកាសលើកដំបូងនេះ វាមានប្រយោជន៍សម្រាប់គាត់។ ជនបង្គោលត្រូវផ្តល់ការយកចិត្តទុកដាក់ដល់អ្នកទៅរៀននៅក្រៅទាំងនេះ។

133. សំ. ទឹកប្រាក់ដែលបងប្អូនផ្ញើពីក្រៅប្រទេស តើប្រកាសឬយ៉ាងណា?

ចំ. ទឹកប្រាក់នេះត្រូវប្រកាស ដោយបញ្ជាក់ថាលុយនេះត្រូវបានបងប្អូនជាអ្នកផ្ញើជូន។ បើមិនប្រកាស យើងមិនអាចយកមកសំអាងសម្រាប់ការចំណាយផ្សេងៗបានទេ។

134. សំ. តើដីធ្លីមានទំហំប៉ុន្មានហិចតា ទើបត្រូវប្រកាស?

ចំ. ដីធ្លីមិនកំណត់ថាប៉ុន្មានការ៉េ ឬហិចតានោះទេ គឺត្រូវប្រកាសទាំងអស់ ឱ្យតែដីធ្លីនោះមានឈ្មោះយើងជាម្ចាស់។

135. សំ. ទ្រព្យសម្បត្តិរបស់ប្រពន្ធ តើប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលឬទេ?

ចំ.ទ្រព្យសម្បត្តិដែលជារបស់ប្រពន្ធមិនតម្រូវឱ្យប្រកាសទេ លើលែងតែទ្រព្យសម្បត្តិដែលជាអចលនទ្រព្យ ដីធ្លី និងផ្ទះសំបែងដែលមានឈ្មោះរបស់យើង (សហកម្មសិទ្ធិករ) ដែលជាប់កាតព្វកិច្ចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល។

136. សំ.ដីធ្លីដែលទទួលបានតាំងពីឆ្នាំ១៩៧៩ តែគ្មានលិខិតបញ្ជាក់ពីភូមិឬ ឃុំ តើត្រូវប្រកាសឬទេ?

ចំ.ទោះមានឯកសារ ឬមិនប្រកាសបញ្ជាក់ពីភូមិឬឃុំ ក៏ដោយ ក៏ត្រូវប្រកាស ដោយដីធ្លីនេះជាទ្រព្យសម្បត្តិរបស់យើង។

137. សំ. តើនៅពេលយើងមិនព្រមទទួលសំណូក តើយើងអាចប្តឹងអ្នកសូកបានឬទេ?

ចំ. ករណីនេះយើងអាចប្តឹងបាន និងត្រូវចូលរួមសហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ។ អង្គភាពនេះរកគ្រប់មធ្យោបាយដើម្បីការពារសុវត្ថិភាពរបស់អ្នកចូលរួមផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ។

138. សំ. បើនាយទាហាន ឈឺកំពុងសម្រាកព្យាបាល មានអាការៈធ្ងន់ធ្ងរ បំពេញឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលមិនកើត តើប្រកាសឬទេ?

ចំ. បើនាយទាហាននេះមិនអាចសរសេរបាន គាត់អាចពឹងពាក់អ្នកដទៃបានឱ្យជួយបំពេញឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ជំនួសបាន ។ ការសម្រាកព្យាបាលជំងឺមិនអាចយកមកធ្វើជាទឡ្ហីករណ៍សម្រាប់ការមិនប្រកាសទ្រព្យសម្បត្តិ និងបំណុលបានទេ។

139. សំ. អ្នកលាឈប់ពីតំណែងដែលបានការឯកភាពពីអង្គភាពហើយ តែមិនទាន់បានការយល់លិខិតកាត់ចេញពីថ្នាក់លើ ត្រូវប្រកាសឬទេ?

ចំ. បើត្រឹមតែការឯកភាពត្រឹមអង្គភាព គាត់ត្រូវប្រកាសជាធម្មតា ព្រោះមិនទាន់មានការឯកភាពចុងក្រោយពីថ្នាក់លើ និងមានលិខិតកាត់ចេញជាស្ថាពរ។



ភ៊ីម៉ីឯកសារ

140. សំ. ផ្ទះបានពីរដ្ឋឲ្យ គ្មានលិខិតស្នាម គ្មានតម្លៃ តើប្រកាសពីតម្លៃយ៉ាងណា?

ចំ. ការប្រកាសតម្លៃរបស់ផ្ទះប្រភេទ ដាក់តាមការពិត ដោយអាចបញ្ជាក់ថាបានពីរដ្ឋ ឬតម្លៃស្មើសូន្យ ។

141. សំ. ការទិញការដូរជូនថ្នាក់ដឹកនាំក្នុងថ្ងៃចូលឆ្នាំខ្មែរ ហើយយកលុយអង្គភាពមកប្រើ តើជាអំពើពុករលួយឬទេ?

ចំ. ការចំណាយក្នុងថ្ងៃបុណ្យប្រពៃណីដែលមិនមានតម្លៃច្រើន ជាទំនៀមទម្លាប់របស់គ្រប់ជាតិសាសន៍ គឺមិនមែនជាអំពើពុករលួយទេ។ ចំពោះអំណោយដល់អង្គភាព គឺមិនខុសច្បាប់ទេ តែអំណោយចំពោះបុគ្គលនៅក្នុងអង្គភាព គឺខុសច្បាប់។

142. សំ. អង្គភាពសុំសក្តិ គ្រឿងឥស្សរិយយស តែតែងតាំងមានការទាមទារប្រាក់ តើជាការពុករលួយឬទេ?

ចំ. មិនមានការអនុញ្ញាតស្របច្បាប់ ការទាមទារប្រាក់ទោះក្នុងរូបភាពណាក៏ដោយ ជាការខុសច្បាប់ និងក៏ជាអំពើពុករលួយ។

143. សំ. តើគោ ក្របី ជ្រូក មាន់ ទា តម្រូវឱ្យប្រកាសឬទេ?

ចំ. គោ ក្របី ជ្រូក មាន់ ទា មិនតម្រូវឱ្យប្រកាសទេ តែចំណូលដែលបានមកពីការលក់សត្វទាំងនោះ ត្រូវប្រកាសក្នុងចំណុចចំណូលសម្រាប់ជាប្រយោជន៍របស់អ្នកប្រកាស។

144. សំ. តើលេខកូដម៉ាស៊ីនទូរស័ព្ទនីមួយៗ ត្រូវប្រកាសដែរ ឬទេ?

ចំ. លេខកូដនៃម៉ាស៊ីនទូរស័ព្ទ មិនប្រកាសទេ ប្រកាសតែលេខទូរស័ព្ទប្រើប្រាស់ដែលក្រុមហ៊ុនផ្តល់ឱ្យបុគ្គលនីមួយៗ។

145. សំ. ឡានវាយកូនកូល ស្គីជិះលើទឹក ម៉ាស៊ីនថតរូប ម៉ាស៊ីនភ្លើង កុំព្យូទ័រ ម៉ាញ៉េ និងវិទ្យុ តើត្រូវប្រកាស ឬទេ?

ចំ. ប្រកាសតែឡានវាយកូនកូល និងស្គីជិះលើទឹក ចំណែកម៉ាស៊ីនថតរូប ម៉ាស៊ីនភ្លើង កុំព្យូទ័រ ម៉ាញ៉េ និងវិទ្យុ មិនតម្រូវឱ្យប្រកាសទេ។

146. សំ. តើព្រះរាជវង្សានុវង្ស ដែលមានតួនាទីជាទីប្រឹក្សា តែមិនមានតួនាទីអ្វីសំខាន់ទេ និងតែងតាំងដោយព្រះរាជក្រឹត្យ គ្រាន់តែជាកិត្តិយស តើប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ?

ចំ. បើតួនាទីទីប្រឹក្សាគ្រាន់តែជាកិត្តិយស ទោះបីតួនាទីតែងតាំងដោយព្រះរាជក្រឹត្យក៏ដោយក៏មិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ ព្រោះតួនាទីនេះគ្រាន់តែជាងារតែប៉ុណ្ណោះ។

147. សំ. បើយើងដឹងថា ចៅក្រមស៊ីសំណូក ហើយគាត់កាត់ក្តីដោយលំអៀង (អយុត្តិធម៌) តើអាចប្តឹង ទៅអង្គភាពប្រឆាំងអំពើពុករលួយបានដែរឬទេ?

ចំ. ការសម្រេចសេចក្តីរបស់ចៅក្រមឱ្យភាគីណាមួយចាញ់ ឬឈ្នះ ជាសិទ្ធិអំណាចរបស់ចៅក្រម អង្គភាពប្រឆាំងអំពើពុករលួយមិនមានសិទ្ធិត្រួតពិនិត្យលើការសម្រេចរបស់ចៅក្រមឡើយ។



វ៉ាង់ឯកសារ

ផ្ទុយទៅវិញ បើការសម្រេចសេចក្តីរបស់តុលាការមិនបានបញ្ជាក់ពីការទទួលសំណូក អង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិគ្រប់គ្រាន់ដើម្បីស៊ើបអង្កេតករណីនេះ។

148.សំ. ទ្រព្យសម្បត្តិជាកេរ ប៉ុន្តែអ្នកទទួលកេរ ត្រូវបានកាត់ឈ្មោះចេញពីបញ្ជីគ្រួសារស្នាក់នៅ តើអ្នកទទួលកេរអាចប្រកាសទ្រព្យសម្បត្តិ ដែលជាកេរនោះបានដែរឬទេ?

ចំ. ការកាត់ឈ្មោះចេញពីបញ្ជីគ្រួសារ មិនមានន័យថាបុគ្គលនោះមិនមានសិទ្ធិទទួលបាននូវកេរមរតកដែលឪពុកម្តាយប្រគល់ជូន បុគ្គលនោះត្រូវប្រកាសអំពីកេរដែលទទួលបាននោះលើទម្រង់ក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល។

149. សំ. តើអាចសុំ soft copy ដែលពាក់ព័ន្ធនឹងបទបង្ហាញនៃឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានរៀបចំដោយអង្គភាពប្រឆាំងអំពើពុករលួយបានដែរទេ?

ចំ. អង្គភាពអាចផ្តល់ជូន soft copy ដែលបានធ្វើបទបង្ហាញទាំងឡាយជូន នៅពេលមានការស្នើសុំ។

150. សំ. ជំនួយការ និងទីប្រឹក្សានៅពេលចប់អាណត្តិ តើត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលបន្តទៀតទេ (លើកទី២)?

ចំ. ការចប់អាណត្តិរបស់ជំនួយការ និងទីប្រឹក្សាត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល។ បុគ្គលទាំងនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ៣០ថ្ងៃយ៉ាងយូរ មុនការបញ្ចប់អាណត្តិ។

151. សំ. តើអង្គភាពប្រឆាំងអំពើពុករលួយ មានអំណាចទៅលើស្ថាប័នអ្វីខ្លះ? ឧទាហរណ៍ដូចជាស្ថាប័នព្រះមហាក្សត្រ?

ចំ. ព្រះមហាក្សត្រជាបុគ្គលដែលមិនអាចរំលោភបានជាដាច់ខាត (ស្មារតីរដ្ឋធម្មនុញ្ញ)។ តាមគោលការណ៍ការអនុវត្តជាសកលនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់នេះអនុវត្តចំពោះអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ គ្រប់បុគ្គលបម្រើការក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងអំណាចតុលាការ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលបានប្រព្រឹត្តបទល្មើសពុករលួយនឹងត្រូវទទួលរងនូវការស៊ើបអង្កេតពីអង្គភាពប្រឆាំងអំពើពុករលួយ។

152. សំ. តើអង្គភាពប្រឆាំងអំពើពុករលួយបានបង្កើតឡើងនៅថ្ងៃណាខែណាឆ្នាំណា? ហើយអ្នកណាជាអ្នកធ្វើច្បាប់នេះ?

ចំ. អង្គភាពប្រឆាំងពលសកម្មភាពពុករលួយត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩៨ បន្ទាប់មករាជរដ្ឋាភិបាលបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយនៅ២០០៦ បន្តអនុវត្តការងារពីអង្គភាពមុន។ ក្រោយពីច្បាប់ប្រឆាំងអំពើពុករលួយបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០ រាជរដ្ឋាភិបាលមានភារកិច្ចរៀបចំស្ថាប័នប្រឆាំងអំពើពុករលួយ (ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ) ក្នុងរយៈពេល៦០ថ្ងៃ។ រាជរដ្ឋាភិបាល

ជាអ្នករៀបចំសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដើម្បីដាក់ជូនទៅរដ្ឋសភាអនុម័តលើច្បាប់នេះ។

153. សំ. ជំនួយការ និងទីប្រឹក្សាគ្រាន់តែជាភ្នាក់ងារជាប់កិច្ចសន្យាតែប៉ុណ្ណោះ ពេលចប់កិច្ចសន្យាគឺចប់ភារកិច្ច ចុះហេតុអ្វីបានជាតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល?

ចំ. ទីប្រឹក្សា និងជំនួយការត្រូវបានកំណត់ដោយច្បាប់ជាអ្នករាជការសាធារណៈដែលតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមានចែងក្នុងចំណុចទី៨ មាត្រា១៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

154. សំ. បើប្តីមានភារកិច្ចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ហើយប្រពន្ធក៏មានភារកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរ ប៉ុន្តែប្រពន្ធនៅបរទេស សូមមេត្តាពន្យល់ក្នុងករណីទ្រព្យសម្បត្តិរួមគ្នា?

ចំ. ក្នុងករណីនេះប្តី និងប្រពន្ធត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចគ្នា ទោះបីប្រពន្ធកំពុងស្ថិតនៅឯបរទេសក៏ដោយ ក៏ត្រូវប្រកាសដែរ។ ទ្រព្យសម្បត្តិរួមត្រូវប្រកាសដូចគ្នា (បើអ្នកប្រកាសជាប្តីត្រូវដាក់ឈ្មោះប្រពន្ធជាសហកម្មសិទ្ធិករ បើអ្នកប្រកាសជាប្រពន្ធត្រូវដាក់ឈ្មោះប្តីជាសហកម្មសិទ្ធិករ)។

155. សំ. បើពេលប្រកាសទ្រព្យសម្បត្តិ និងបំណុល អ្នកប្រកាសមិនទាន់មានរថយន្ត តែក្រោយពេលប្រកាសបានទិញ រថយន្ត ដោយទទួលបានលុយនោះតាមរយៈដេញតុងទីន។ តើលុយនោះជាលុយស្របច្បាប់ដែរឬទេ?

ចំ. ចំណូលពីតុងទីនមិនមែនជាចំណូលខុសច្បាប់ទេ បើលុយសម្រាប់ទិញឡានពីលុយតុងទីន លុយនេះក៏ស្របច្បាប់ដែរ។ តុងទីនមិនត្រូវបានច្បាប់ហាមឃាត់មិនឱ្យលេងនោះទេ។

156. សំ. យើងបានចូលហ៊ុន (ដាក់ហ៊ុន) ទៅក្នុងក្រុមហ៊ុនឯកជនមួយ (មិនមែនជាអគ្គនាយកក្រុមហ៊ុនទេ) តើទ្រព្យសម្បត្តិដែលបានចូលហ៊ុននេះ ត្រូវបានលើកយកមកប្រកាសដែរឬទេ?

ចំ. ចំណូលនេះជាចំណូលស្របច្បាប់។ តែត្រូវពិនិត្យមើលថាការចូលហ៊ុនក្នុងក្រុមហ៊ុនមួយត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬច្បាប់ដទៃទៀតឬទេ បើមិនមានការហាមឃាត់ យើងអាចប្រកាសពីទ្រព្យសម្បត្តិដែលបានចូលភាគហ៊ុន។

157. សំ. ករណីនៃការចូលហ៊ុនគ្នាទិញដីមួយកន្លែង ហើយដីនេះបានដាក់ឈ្មោះយើង ជាម្ចាស់កម្មសិទ្ធិដីធ្លីមួយកន្លែងនោះ។ តើក្នុងករណីនេះ តើយើងត្រូវប្រកាសដែរឬទេ? ហើយប្រសិនបើគេត្រូវឱ្យប្រកាសតើត្រូវប្រកាសដោយរបៀបណា?

ចំ. បើមានឈ្មោះយើងជាម្ចាស់ដីសហកម្មសិទ្ធិ យើងត្រូវប្រកាស ហើយត្រូវបញ្ចូលឈ្មោះសហកម្មសិទ្ធិករទាំងអស់ក្នុងករណីឯកសារបញ្ជាក់ដីធ្លីអ្នកទាំងនោះមានឈ្មោះបុគ្គលដែល

https://www.facebook.com/Voangeksa

បានចូលភាគហ៊ុនក្នុងការទិញដីថ្មីខាងលើ។

158. សំ. អំពីព័ត៌មានស្វាមី ឬភរិយា និងកូន តើកូនប្រសាដែលរស់នៅក្នុងបន្ទុកអាចសរសេរក្នុងព័ត៌មានបានដែរឬទេ? (នៅស្រោមសំបុត្រខាងក្រៅ)

ចំ. បុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវផ្តល់ព័ត៌មានត្រឹមតែសហព័ទ្ធ និងកូនតែប៉ុណ្ណោះ។ ចំពោះកូនប្រសាដែលនៅក្នុងបន្ទុក ឬក្រៅបន្ទុកមិនត្រូវក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលនោះទេ។

159. សំ. ក្រោយពេលប្រកាសទ្រព្យសម្បត្តិហើយ មានលុយយកទៅដាក់ធនាគារ តើនេះមានការពាក់ព័ន្ធយ៉ាងដូចម្តេច?

ចំ. ធនាគារជាកន្លែងស្របច្បាប់ក្នុងការទទួលបញ្ញើប្រាក់គ្រប់ប្រភេទ។ ការយកលុយទៅដាក់នៅធនាគារធ្វើមានទុនសម្រាប់ការវិនិយោគដែលធ្វើឱ្យសេដ្ឋកិច្ចមានការអភិវឌ្ឍ។ ការប្រកាសទ្រព្យសម្បត្តិ និងបំណុល មានទិសដៅមួយដើម្បីឱ្យបុគ្គលគ្រប់រូបយកប្រាក់របស់ខ្លួនទៅផ្ញើនៅធនាគារ។ ការរក្សាទុកលុយនៅផ្ទះមិនមានផលប្រយោជន៍ដល់ការអភិវឌ្ឍប្រទេសជាតិឡើយ។

160. សំ. ប្រពន្ធជាប្រធាន ឬម្ចាស់ក្រុមហ៊ុន ក្រោយពេលប្រកាសទ្រព្យសម្បត្តិនិងបំណុលក៏មានអចលនទ្រព្យថ្មីទៀត រួមគ្នាជាមួយប្រពន្ធដែលទ្រព្យនេះបានពីចំណូលរបស់ប្រពន្ធទេ តើយើងត្រូវប្រកាសយ៉ាងដូចម្តេច?

ចំ. ទ្រព្យសម្បត្តិរបស់ប្រពន្ធសុទ្ធសាធមិនអាចប្រកាសបានទេ តែបើមានឈ្មោះយើងជាសហកម្មសិទ្ធិដែរត្រូវប្រកាស។ បើកំណើនអចលនទ្រព្យកើតមានក្រោយការប្រកាសដែលជាទ្រព្យរបស់ប្រពន្ធ យើងត្រូវបញ្ជាក់ក្នុងចំណុចប្រភពហិរញ្ញប្បទានថាទ្រព្យនេះបានមកពីការរកស៊ីរបស់ប្រពន្ធ។

161. សំ. តើចំពោះបុរសដែលមានប្រពន្ធច្រើន ឧទាហរណ៍មានប្រពន្ធ ២ ឬ ៣ នាក់ តើបុរសនោះត្រូវប្រកាសក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលយ៉ាងដូចម្តេច?

ចំ. តាមស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ឯកពន្ធភាព បុរស ឬស្ត្រីមានសិទ្ធិរួមរស់ជាមួយប្តី ឬប្រពន្ធតែម្នាក់ប៉ុណ្ណោះ។ ករណីនេះអ្នកប្រកាសទ្រព្យសម្បត្តិ និងបំណុលដែលជាបុរស ប្រកាសឈ្មោះប្រពន្ធតែមួយប៉ុណ្ណោះ។

162. សំ. អ្នកឡើងតំណែងថ្មីដែលតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល តើទ្រព្យសម្បត្តិ និងបំណុលរបស់គាត់ត្រូវគិតចំណុចចាប់ពីពេលណាមក?

ចំ. បុគ្គលដែលទទួលតំណែងថ្មី ហើយដែលតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវ

ប្រកាសក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយការតែងតាំង។ ចំណែកឯទ្រព្យសម្បត្តិ និងបំណុលរបស់គាត់ត្រូវគិតចំណុចចាប់ផ្តើមនៅពេលដែលគាត់ប្រកាសនោះ (ប្រកាសលើកទី១ និងមិនចាត់ទុកជាប្រកាសលើកដំបូងដូចឆ្នាំ២០១១ នេះទេ)។

163. សំ. តើអង្គភាពប្រឆាំងអំពើពុករលួយមានសុឆន្ទៈបែបណាចំពោះការគ្រប់គ្រងសង្គមនាពេលអនាគត? ព្រោះក្រោយពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានផ្សព្វផ្សាយ និងចូលជាធរមានមានមន្ត្រីសាធារណៈ មួយចំនួនមានការភ័យព្រួយលើ សកម្មភាពការងាររបស់ខ្លួន ឬអាចនិយាយបានថាវាជំរុញឱ្យមាន ភាពអសកម្មលើកិច្ចការសង្គមដោយហេតុខ្វះប្រាក់ឧបត្ថម្ភការងារ និងមធ្យោបាយ ប្រេងឥន្ធនៈ ខ្វះមន្ត្រី និងបុគ្គលិក និងមានប្រជាពលរដ្ឋអាជីវកម្មតូចតាចជាច្រើន ត្រូវរងការពិន័យឬទទួលទណ្ឌកម្មដោយការអនុវត្តច្បាប់នានា។

ចំ. កង្វះខាត និងតម្រូវការក្នុងការបំពេញការងាររបស់មន្ត្រីរាជការ និងប្រជាពលរដ្ឋគ្រប់រូប មិនត្រូវយកមកធ្វើជាបុព្វហេតុសម្រាប់ការប្រព្រឹត្តអំពើពុករលួយ។ បុគ្គលគ្រប់រូបបើគ្មានការលើកលែងដោយច្បាប់ មិនថាឡើយប្រជាពលរដ្ឋ ឬអាជីវករតូចតាច ឬមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធត្រូវមានកាតព្វកិច្ចគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយរួមទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយផងដែរ។ ការប្រព្រឹត្តបទល្មើសត្រូវទទួលរងនូវការផ្តន្ទាទោសតាមការកំណត់របស់ច្បាប់។

164. សំ. តើបុគ្គលដែលយកប្រាក់កម្រៃពីមន្ត្រីរាជការ ដែលមិនបានមកបំពេញភារកិច្ច ចាត់ទុកថាជាអំពើពុករលួយដែរឬទេ?

ចំ. មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធត្រូវបំពេញភារកិច្ចតាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃយោធិន។ បុគ្គលដែលមិនបានមកបំពេញការងារជាកំហុសមួយ ចំណែកបុគ្គលដែលទទួលយកកម្រៃពីមន្ត្រីរាជការដែលមិនបានមកបំពេញភារកិច្ចជាកំហុសមួយទៀតដែលចាត់ទុកជាអំពើពុករលួយ។

165. សំ. តើក្នុងប្រទេសកម្ពុជាយើង មានអង្គភាពណាមួយជាអ្នកទទួលខុសត្រូវត្រួតពិនិត្យការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ? ហើយចំនួនបុគ្គលិកទាបបំផុតនៃអង្គភាពប្រឆាំងអំពើពុករលួយប៉ុន្មាន? ខ្ពស់បំផុតចំនួនប៉ុន្មាន?

ចំ. អង្គភាពប្រឆាំងអំពើពុករលួយជាស្ថាប័នមួយស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យផ្ទាល់ពីរាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយដែលមានសមាសភាពចំនួន ១១រូប មកពីក្រសួង ស្ថាប័នផ្សេងៗ ក៏ជាអ្នកឃ្លាំមើលពីសកម្មភាពការងារអង្គភាពប្រឆាំងអំពើពុករលួយ។ មន្ត្រីរាជការទាំងអស់នៃអង្គភាពប្រឆាំងអំពើពុករលួយត្រូវប្រកាសទ្រព្យសម្បត្តិ

និងបំណុលចាប់ពីថ្នាក់ទាបបំផុតដែលមន្ត្រីក្រសួង ស្ថាប័នផ្សេងៗតម្រូវឱ្យប្រកាសតែមន្ត្រីដែលមានឋានៈចាប់ពីប្រធាននាយកដ្ឋាន ឬឋានន្តរសក្តិវរសេនីយ៍ឯក។ រាល់រយៈពេលមួយឆ្នាំម្តង មន្ត្រីរាជការទាំងអស់ត្រូវដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីម៉ាស៊ីន Polygraph (ឧបករណ៍វាស់ស្ទង់ការភូតកុហក)។ អង្គភាពប្រឆាំងអំពើពុករលួយបានបង្កើតផ្នែកស៊ើបអង្កេតផ្ទៃក្នុង ដើម្បីត្រួតពិនិត្យ រាល់ទង្វើទាំងឡាយរបស់មន្ត្រីរាជការនៃអង្គភាពប្រឆាំងអំពើពុករលួយ។ ក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងត្រូវបង្កើតឡើងសម្រាប់កម្រិតព្រំដែននៃការទទួល ផ្តល់អំណោយ ការចូលរួមក្នុងពិធីកម្សាន្ត ការហូបចុក និងសកម្មភាពផ្សេងៗទៀតរបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

166. សំ. តើការស្នក ឬទទួលសំណូកត្រឹមកម្រិតណាដែលចាត់អាចទុកថាជាអំពើពុករលួយ?

ចំ. បទល្មើសពុករលួយជាបទល្មើសទម្រង់ មិនមែនជាបទល្មើសសម្ភារៈដូចបទល្មើសព្រហ្មទណ្ឌផ្សេងៗ។ បទបញ្ញាត្តិនុគ្រោះ បទជំនួញឥទ្ធិពលអកម្ម និងបទរំលោភអំណាច បទសម្លុតគំរាមបទរារាំងនិងការជ្រៀតជ្រែកការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ សុទ្ធតែជាបទល្មើសពុករលួយដែលអាចប្រព្រឹត្តឡើង ក្រោមរូបភាពមិនមានការបង្ហាញនូវការទទួល ឬផ្តល់ឱ្យនូវទឹកប្រាក់ ឬអត្ថប្រយោជន៍ផ្សេងៗទៀត។ ក្នុងន័យនេះ សូម្បីតែ សូន្យដុល្លារ ក៏ចាត់ទុកជាបទល្មើសពុករលួយដែរ។

167. សំ. តើឆ្នាំ២០១១ នេះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រឹមមន្ត្រីកម្រិតណាខ្លះ?

ចំ. ជាទូទៅការប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកដំបូងក្នុងឆ្នាំ២០១១នេះ គឺអនុវត្តចំពោះមន្ត្រីដែលមានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង ឬឋានន្តរសក្តិវរសេនីយ៍ឯក។ សមាសភាពមន្ត្រីដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល លើកលែងតែមន្ត្រីដែលកំណត់ក្នុងចំណុចទី៥(មន្ត្រីតែងតាំងដោយប្រកាស) និងទី៧ (ថ្នាក់ដឹកនាំសង្គមស៊ីវិល) ដែលមិនទាន់តម្រូវឱ្យប្រកាស។

168. សំ. បើឃើញមន្ត្រី ធំ តូច បានប្រព្រឹត្តអំពើពុករលួយ តើរាយការណ៍ទៅណា? (សុំលេខទូរស័ព្ទ) ក្រុមការងារប្រឆាំងអំពើពុករលួយ ។

ចំ. យោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមានតែអង្គភាពប្រឆាំងអំពើពុករលួយប៉ុណ្ណោះដែលមានសិទ្ធិកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការ។ បុគ្គលទាំងឡាយណាដែលដឹងពីរឿងហេតុនៃបទល្មើសពុករលួយអាចប្តឹងតាមរយៈ៖

- ប្រអប់សំបុត្រដែលមាននៅមុខអង្គភាពប្រឆាំងអំពើពុករលួយ (អតីតអគ្គបញ្ជាការដ្ឋាន

នៃកងយោធពលខេមរភូមិន្ទ) និងមុខអតីតសណ្ឋាគារខេមរា (ខាងត្បូងផ្សារថ្មី)

- ប្តឹងផ្ទាល់នៅការិយាល័យទទួលពាក្យបណ្តឹងនៃអង្គភាពប្រឆាំងអំពើពុករលួយ
- ប្រអប់សំបុត្រប្រៃសណីយ៍ PO Box 626 ដោយមិនគិតលុយនៅគ្រប់បញ្ជរប្រៃសណីយ៍រាជធានីខេត្ត
- Hot Line និងលេខទូរស័ព្ទដែលនឹងផ្តល់ជូននៅពេលក្រោយដោយអង្គភាពប្រឆាំងអំពើពុករលួយ។

169. សំ. តើក្រុមប្រឹក្សាឃុំត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលអ្វីខ្លះ? តម្លៃស្មើប៉ុន្មានដុល្លារបានតម្រូវឱ្យប្រកាស?

ចំ. ក្រុមប្រឹក្សាឃុំជាបុគ្គលដែលកំណត់ច្បាប់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចបុគ្គលដទៃទៀតដែលមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ដូចនេះ គាត់ត្រូវប្រកាសតាមទម្រង់ និងខ្លឹមសារនៃឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែលផ្តល់ជូនដោយអង្គភាពប្រឆាំងអំពើពុករលួយ។ មានតែគ្រឿងអលង្ការ ឬនាឡិកាទេដែលកំណត់ឱ្យប្រកាសចាប់ពី ៤លានរៀល។

170. សំ. តើការផ្តល់សារគុណពេលបំពេញភារកិច្ចចាត់ទុកជាអំពើពុករលួយដែរឬទេ?

ចំ. ការផ្តល់អំណោយ ឬសារគុណដល់ក្រសួង ស្ថាប័នមិនមែនជាអំពើពុករលួយទេ តែបើផ្តល់ជូនបុគ្គលជាអំពើពុករលួយ។ គ្មានការអនុញ្ញាតដោយច្បាប់ មន្ត្រីរាជការមិនអាចទទួលយកអំណោយ ឬសារគុណក្នុងពេលបំពេញភារកិច្ចពីបុគ្គលណាឡើយ ព្រោះវាអាចមានទំនាស់ផលប្រយោជន៍ និងមានភាពលំអៀងក្នុងការងារ។

171. សំ. ប្រធានតែងតាំងបែងចែកឱ្យអនុប្រធានគ្រប់គ្រងការិយាល័យណា១ តែប្រធានបានរំលោភការងារទាំងស្រុងលើអនុប្រធានជំនាញ ដោយអនុប្រធានបានមានតែឈ្មោះ បើមានករណីបទល្មើសជាក់ស្តែងតើអនុប្រធានមានទោសដែរ ឬទេ? ក្នុងច្បាប់ប្រឆាំងអំពើពុករលួយដែរឬទេ។

ចំ. ទោះបទល្មើសពុករលួយក្តី បទល្មើសព្រហ្មទណ្ឌឯទៀតក្តី អ្នកប្រព្រឹត្ត អ្នករួមប្រព្រឹត្ត អ្នកផ្សំគំនិត អ្នកផ្តើមគំនិត អ្នកផ្តល់មធ្យោបាយ និងអ្នកប៉ុនប៉ង (កំណត់ដោយច្បាប់)... ត្រូវទទួលទោសដូចគ្នាក្នុងករណីបាន និងកំពុងប្រព្រឹត្តបទល្មើសណាមួយ។ ករណីខាងលើបុគ្គលនោះអាចរួចផុតពីការចោទប្រកាន់ បើស្ថិតក្នុងតំនាបរបស់ប្រធាន តែបើគាត់បានចូលរួមដោយបង្ហាញឆន្ទៈផ្ទាល់នឹងត្រូវទទួលទោសដូចប្រធានរបស់គាត់ដែរ។



ភិតិសិក្សាសារ

172. សំ. ការប្រកាសគ្រឿងអលង្ការ និងប្រាក់ តើអាចលិចលីទៅខាងក្រៅដែរឬទេ?

ចំ. ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដែលរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានចាត់ទុកឯកសារដែលបានរក្សាការសម្ងាត់ខ្ពស់បំផុត។ ពុំមានបុគ្គលណាម្នាក់អាចពិនិត្យមើលនូវឯកសាររបស់បុគ្គលណាមួយទៀត ក្រៅតែពីមូលហេតុចាំបាច់នៃការស៊ើបអង្កេតអំពើពុករលួយ។ ទោះបីបុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុលបានប្រកាសពុំពេញលេញក៏ដោយក៏មិនអាចបណ្តាលឱ្យមានការលិចលីពីស្ថានភាពគ្រឿងអលង្ការ និងប្រាក់របស់បុគ្គលនោះចេញពីអង្គភាពប្រឆាំងអំពើពុករលួយ។ បើបុគ្គលនេះប្រកាស ឬមិនប្រកាសឱ្យគេដឹង ជាសិទ្ធិរបស់គាត់។

173. សំ. តើក្រុមប្រឹក្សាឃុំសង្កាត់ជាមន្ត្រីមុខងារសាធារណៈ ឬមុខងារនយោបាយ ហេតុអ្វីបានជាតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល?

ចំ. ទោះជាមន្ត្រីមុខងារសាធារណៈ ឬ ជាមន្ត្រីនយោបាយឱ្យតែស្ថិតក្នុងសមាសភាពដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកំណត់ដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយជាជាពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលតម្រូវឱ្យប្រកាស។

174. សំ. តើទ្រព្យសម្បត្តិមានតម្លៃស្មើប៉ុន្មានពាន់ដុល្លារដែលច្បាប់តម្រូវឱ្យប្រកាស?

ចំ. មានតែគ្រឿងអលង្ការ និងនាឡិកាតែប៉ុណ្ណោះដែលកំណត់តម្លៃនៅពេលទទួលបានចាប់ពី៥លានរៀល ក្រៅពីនេះ ទោះបីក្នុងពេលទទួលបានមានតម្លៃប៉ុណ្ណាក៏ដោយ ដូចជាអចលនវត្ថុ យានយន្តនិងគ្រឿងចក្រ ព្រមទាំងចំណុចផ្សេងទៀត គឺតម្រូវឱ្យប្រកាស។

175. សំ. តើប្រាក់ជំពូក និងប្រាក់លើកទឹកចិត្តចាប់ពីកម្រិតប៉ុន្មានទើប ហៅថាជាប្រាក់អំពើពុករលួយ?

ចំ. ការប្រើប្រាស់សាច់ប្រាក់ដែលមិនចំទិសដៅ និងគ្មានការអនុញ្ញាតត្រឹមត្រូវ ត្រូវចាត់ទុកជាអំពើពុករលួយ ទោះបីជាប្រាក់ជំពូក និងប្រាក់លើកទឹកចិត្តក្នុងកម្រិតណាក៏ដោយ។

176. សំ. តើអ្នកកសិករ អាជីវករ នគញ្ញា និងប្រជាពលរដ្ឋទូទៅតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលដែរឬទេ? មូលហេតុអ្វីបានជាមិនប្រកាសជាទូទៅ?

ចំ. ក្រៅពីសមាសភាពបុគ្គលដែលកំណត់ក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បុគ្គលផ្សេងទៀតមិនតម្រូវឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ។ ការមិនប្រកាសជាទូទៅដោយបុព្វហេតុ ទី១. មូលហេតុច្បាប់ដែលតម្រូវឱ្យប្រកាសក្នុងកម្រិតដែល



វ៉ាងឯកសារ

បានកំណត់ ទី២. អង្គភាពពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់ ដូចនេះយើងអនុវត្តក្នុងកម្រិតសាមញ្ញសិន ទី៣. សមាសភាពដែលមិនប្រកាសភាគច្រើនស្ថិតក្នុងវិស័យឯកជនដែលពុំសូវទទួលរង ឬមិនមានអំណាចសាធារណៈដែលអាចឈានទៅរកការប្រព្រឹត្តអំពើពុករលួយ។

177. សំ. ក្រុមប្រឹក្សាឃុំប្រកាសទ្រព្យសម្បត្តិ និងបំណុល នៅពេលដែលបម្រើការងារក្នុងអាណត្តិ។ នៅពេលគាត់អស់អាណត្តិបម្រើការងារ(មិនជាប់ឆ្នោត) តើឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលនេះ ប្រើប្រាស់បន្តទៀតដែរឬទេ?

ចំ. ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយក្នុងរយៈពេលយ៉ាងតិច១០ឆ្នាំ ចាប់ពីទទួលស្លាកឯកសារ។ ទោះបីអ្នកប្រកាសទ្រព្យសម្បត្តិ និងបំណុលបញ្ចប់អាណត្តិការងារក៏ដោយ ក៏ឯកសារនេះមិនត្រូវបានប្រគល់ជូនសាមីខ្លួន និងបន្តរក្សាទុកនៅអង្គភាព។ ឯកសារនេះនៅមានសុពលភាពប្រើប្រាស់សម្រាប់កិច្ចការទាំងឡាយដែលអាចកើតចេញពីទង្វើរបស់បុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុល ទោះបីបុគ្គលនោះបានបញ្ចប់មុខងាររបស់ខ្លួនហើយក៏ដោយ។

178. សំ. តើជាក់ស្តែងមន្ត្រីតែងតាំងដោយប្រកាសត្រឹមថ្នាក់ណា ដែលត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល?

ចំ. ក្រុមជនបង្គោលនឹងកំណត់ពីមន្ត្រីដែលតែងតាំងដោយប្រកាសឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល។ អង្គភាពប្រឆាំងអំពើពុករលួយនឹងរៀបចំបញ្ជីមន្ត្រីប្រភេទនេះបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយថាមន្ត្រីកម្រិតណាដែលតម្រូវឱ្យធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុល។ ឧទាហរណ៍ មន្ត្រីគយ និងរដ្ឋាករ មន្ត្រីពន្ធដារ ប្រធានមន្ទីរតាមបណ្តាខេត្តក្រុង អធិការស្រុកខណ្ឌ មន្ត្រីបម្រើការនៅតាមបណ្តាច្រកទ្វារព្រំដែន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ជាដើមដែលអាចនឹងត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលនៅពេលខាងមុខ។

179. សំ. ក្នុងអង្គភាពមួយមានកើតអំពើពុករលួយ តើក្នុងនាមមន្ត្រីថ្នាក់ក្រោមអាចរាយការណ៍អំពើពុករលួយតាមរយៈណាដែលជាការសម្ងាត់?

ចំ. គ្រប់បុគ្គលទាំងអស់ដែលដឹងរឿងហេតុនៃអំពើពុករលួយអាចរាយការណ៍ពីព័ត៌មានមកអង្គភាពប្រឆាំងអំពើពុករលួយ ឬការិយាល័យរាជធានី ខេត្តក្រុងប្រឆាំងអំពើពុករលួយ ទោះបីបុគ្គលនោះជាប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឬមន្ត្រីឯទៀតដែលមានឋានៈសង្គមក្នុងកម្រិតណាមួយក៏ដោយ។

180. សំ. តើការប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកដំបូងត្រូវបញ្ចប់នៅពេលណា?



វ៉ាំងឯកសារ

ចំ. យោងសេចក្តីសម្រេចលេខ០០៣ /១១ លស.អបព ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១១ ប្រការ៥ បានកំណត់កាលបរិច្ឆេទចុងក្រោយនៃការឈប់ទទួលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល គឺនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១។

181. សំ. អ្នកដែលមិនទាន់មានសិទ្ធិប្រកាសក្នុងឆ្នាំ២០១១នេះ តើការប្រកាសរបស់គាត់នៅពេលបន្ទាប់ចាត់ទុកថាជាការប្រកាសលើកដំបូង ដែរឬទេ?

ចំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលឆ្នាំ២០១១ ជាការប្រកាសលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងរយៈពេលរាប់ពាន់ឆ្នាំមកហើយ មិនដែលធ្លាប់បានអនុវត្ត។ ឯការប្រកាសក្រោយឆ្នាំ២០១១ គឺជាការប្រកាសលើកទី១ មិនចាត់ទុកជាការប្រកាសលើកដំបូងទេ។

182. សំ. ការប្រកាសទ្រព្យសម្បត្តិជាអចលនវត្ថុ (ដី) ដែលជាទ្រព្យរួមប្តី ប្រពន្ធ តើត្រូវប្រកាសទ្រព្យសម្បត្តិផ្ទាល់ខ្លួននេះដោយរបៀបណា?

ចំ. ទោះជាសហកម្មសិទ្ធិករនោះជាប្តី ឬប្រពន្ធ សាច់ញាតិ មិត្តភក្តិ ឬអ្នកដទៃក៏ដោយ ក៏តម្រូវឱ្យប្រកាសពីអចលនវត្ថុនោះ និងបញ្ជាក់ឈ្មោះសហកម្មសិទ្ធិករឱ្យបានច្បាស់លាស់។

183. សំ. ក្នុងករណីដែលញាតិសន្តាននៅបរទេសពឹងឱ្យឈរឈ្មោះទិញដី ឬផ្ទះ តើការប្រកាសទ្រព្យសម្បត្តិត្រូវធ្វើដូចម្តេច?

ចំ. ក្នុងករណីនេះតម្រូវឱ្យបុគ្គលដែលបានឈរឈ្មោះនោះត្រូវប្រកាស ហើយគ្រាន់តែធ្វើការបញ្ជាក់ពីប្រភពថាបានមកពីញាតិសន្តានដែលផ្តល់លុយឱ្យបុគ្គលនោះទិញជំនួស និងឈរឈ្មោះឱ្យ។

184. សំ. ការប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវចាត់ទុកជាការសម្ងាត់ខ្ពស់បំផុត ប៉ុន្តែបើព័ត៌មាននៃទ្រព្យសម្បត្តិនេះត្រូវលេចចេញទៅជាសាធារណៈ តើស្ថាប័នណាទទួលខុសត្រូវ? ហើយសាមីជនរងគ្រោះមានសិទ្ធិប្តឹងទារសំណងបានដែរឬទេ?

ចំ. ច្បាប់តម្រូវឱ្យអង្គភាពប្រឆាំងអំពើពុករលួយរក្សាស់ណុំឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទុកជាការសម្ងាត់ខ្ពស់បំផុត។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តិបទល្មើសនឹងទទួលទោសតាមច្បាប់កំណត់។

185. សំ. ករណីដីភូមិ ឬដីស្រែចម្ការឪពុកចែកឱ្យ តែមិនទាន់មានបណ្តាំមរតក តើអាចប្រកាសបានដែរឬទេ?

ចំ. បណ្តាំមរតកកើតចេញពីការបន្សល់ទុកទ្រព្យសម្បត្តិរបស់សន្តតិជនផ្តល់ឱ្យមរតកជន។



វាំងឯកសារ

ក្នុងករណីមិនទាន់មានឈ្មោះរបស់អ្នកប្រកាសក្នុងឯកសារបណ្ដាំមរតក បុគ្គលនោះមិនអាចប្រកាសអំពីទ្រព្យដែលជាដីស្រែចម្ការនោះបានទេ។

186. សំ. គុងទីនមិនទាន់ដេញ តើត្រូវប្រកាសដែរឬទេ?

ចំ. លុយពីការលេងគុងទីនជាប្រភពចំណូលមួយដែលមិនត្រូវបានកំណត់ដោយច្បាប់ថាជាចំណូលមិនស្របច្បាប់។ យើងអាចប្រកាសបានក្នុងលក្ខខណ្ឌប៉ាន់ស្មាននៃចំនួនចំណូលនេះ ព្រោះវាជាចំណូលរបស់យើងស្របច្បាប់។

187.សំ. ការបើកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលដោយចិត្តឯង តើខុសច្បាប់ដែរឬទេ?

ចំ. ឯកសារដែលតម្កល់នៅអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានរក្សាទុកជាការសម្ងាត់ខ្ពស់បំផុត។ ឯកសារដែលនៅសាមីខ្លួន សាមីខ្លួនអាចមានសិទ្ធិគ្រប់យ៉ាងថាបើកមើល ឬមិនបើកមើល ហើយក៏គ្មានទោសដែរ។

188. សំ. តើគេអាចយកឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលមកបញ្ជាក់នៅតុលាការបានដែរឬទេ ដើម្បីធ្វើជាភស្តុតាង?

ចំ. បុគ្គលទាំងអស់អាចយកឯកសារទាំងឡាយធ្វើជាភស្តុតាងនៅតុលាការ។ ឯកសារនេះអាចយកទៅប្រើនៅគ្រប់ករណីណាក៏បាន ព្រោះជាសិទ្ធិរបស់សាមីជន។

189. សំ. ប្រកាសបាន៣ខែរួច ហើយ៧ខែក្រោយ គាត់គាស់បានកំណប់ តើត្រូវប្រកាសដែរឬទេ?

ចំ. សាមីជនត្រូវប្រកាសនៅលើកទី២ ដោយបញ្ជាក់ប្រភពថាបានមកពីការគាស់កំណប់ដែលមានការដឹងឮគ្រប់គ្រាន់ពីសាក្សី។

190. សំ. ឈ្មោះក្រុមហ៊ុនកំពុងតែរត់ច្បាប់ ប៉ុន្តែមិនទាន់កាលកំណត់ប្រកាសដំបូង តើអាចប្រកាសលើកដំបូងបានដែរឬទេ?

ចំ. ការប្រកាសនេះជាការប្រកាសរបស់សាមីខ្លួនផ្ទាល់។ បើក្រុមហ៊ុននោះដឹកនាំដោយសាមីជនត្រូវប្រកាស ព្រោះយើងមានពាក្យស្នើសុំ។

191. សំ. តើអង្គភាពប្រឆាំងអំពើពុករលួយរក្សាទុកឯកសារយ៉ាងណាដើម្បីឱ្យមានសុវត្ថិភាព?

ចំ. ច្បាប់តម្រូវឱ្យអង្គភាពរក្សាឯកសារនោះ ក្នុងលក្ខខណ្ឌរក្សាការសម្ងាត់ខ្ពស់បំផុត។ អង្គភាពក៏នឹងត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីធានានូវសុវត្ថិភាពនៃឯកសារ។

192. សំ. ពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្ម-ពាណិជ្ជកម្ម ហេតុអ្វីបានជាអង្គភាពប្រឆាំងអំពើពុករលួយចាំបាច់ឱ្យមន្ត្រីរាជការសរសេរចូលក្នុងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល?



វាំងឯកសារ

https://www.facebook.com/Voangeksa

ចំ. អាជីវកម្ម-ពាណិជ្ជកម្ម អាចទទួលបានកម្រៃដែលនាំឱ្យមានកំណើនទ្រព្យសម្បត្តិ។ ជាផលប្រយោជន៍របស់សាមីជនទៅវិញ ពេលយើងត្រូវការចំណាយក្នុងការពង្រីកទុន និងវិនិយោគបន្ត។



វិចិត្រឯកសារ